ព្រៃលិចទឹកបឹងទន្លេសាបពីមួយថ្ងៃទៅមួយថ្ងៃគឺកំពុងតែទទួលរងនូវការ បំផ្លិចបំផ្លាញយ៉ាងខ្លាំង។កត្តាដែលបំផ្លិចបំផ្លាញព្រៃលិចទឹកទាំងនោះមានដូចជា: កំណើនប្រជាជននៅតំបន់បឹងទន្លេសាប មានការកើនឡើងខ្ពស់ ការរានព្រៃលិចទឹកដើម្បីធ្វើស្រែ ចំការ ការកាប់ធ្វើអុសនិងធ្យូងរបស់ប្រជាជន ការកាប់ព្រៃលិចទឹកធ្វើសំរាស់ និងឧបករណ៍នេសាទ ភ្លើងឆេះព្រៃលិចទឹក និងការបំពុលទឹក។ ការបាត់បង់ព្រៃលិចទឹកបឹងទន្លេសាប ពិតជាបានជះឥទ្ធិពល ...់ និងប្រយោលដល់ជីវិតមនុស្ស សត្វ និងបរិស្ថាននៅតំបន់បឹងទន្លេសាប។





F14

សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

...យភូមិន្ទភ្នំពេញ
...សាស្ត្របរិស្ថាន

Sustainable Livelihoods

# ព្រៃលិចទឹក បឹងទន្លេសាប



មិនា - ២០០៤

# ព្រៃលិចទឹក
# បឹងទន្លេសាប


រៀបរៀងដោយ : លោក គង់ ចំណាប់

លោក វ៉ា វុទ្ធី

កែសំរួលដោយ : លោក ម៉ក់ សិទ្ធិរិទ្ធ



ឧបត្ថម្ភដោយ : សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)

: អង្គការអុកស្វាមអាមេរិកកាំង (Oxfam-us)

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងធំធេងចំពោះលោក **ម៉ក់ សិទ្ធិរិទ្ធ** ជានាយកប្រតិបត្តិ *សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល* (FACT) ដែលបានជួយគាំទ្រគ្រប់បែបយ៉ាងទាំងគំនិត និងសំភារៈផ្សេងៗ ដល់រូបខ្ញុំទាំងពីរនាក់ ហើយនិងលោក **ហម គីមគង់** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថាន ដែលបានបញ្ជូនយើងខ្ញុំទាំងពីររូបមកធ្វើការស្រាវជ្រាវពីព្រៃលិចទឹកបឹងទន្លេសាបនៅ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) និងផ្តល់ជាមតិយោបល់ផ្សេងៗ។ គុណបំណាច់របស់លោកទាំងពីរពិតជាបានរួមចំណែកក្នុងភាពខ្វះខាតនូវឯកសារស្តីពី ព្រៃលិចទឹកបឹងទន្លេសាប ហើយនេះពិតជាវិភាគទានមួយជូនដល់អ្នកស្រាវជ្រាវទាំងឡាយ ដែលចាប់អារម្មណ៍នឹងបញ្ហានេះដែរ។

ហើយសូមថ្លែងអំណរគុណផងដែរចំពោះ កញ្ញា លាង កញ្ញា, លោក ប៉ែន វង្សី, លោក តែ សុខឃឿន, កញ្ញា វន វិច្ឆិកា, កញ្ញា ស្រ៊ុន ចិន្តា ព្រមទាំងមិត្តទាំងអស់ ដែលតែងតែបានផ្តល់នូវមតិយោបល់ព្រមទាំងរូបភាពជាច្រើនដល់យើងខ្ញុំទាំងពីរ។

ជាចុងបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យជូនដល់អ្នកទាំងអស់គ្នាជួបតែពុទ្ធពរ ទាំងប្រាំប្រការគឺ: អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ។

# មាតិកា

១. សេចក្តីផ្តើម ........ ១
២. ប្រវត្តិព្រៃលិចទឹក ........ ២
៣. របាយព្រៃលិចទឹកនៅបឹងទន្លេសាប ........ ៤
៣.១ ខេត្តសៀមរាប ........ ៧
៣.២ ខេត្តបាត់ដំបង ........ ៩
៣.៣ ខេត្តកំពង់ឆ្នាំង ........ ១០
៣.៤ ខេត្តពោធិ៍សាត់ ........ ១២
៣.៥ ខេត្តកំពង់ធំ ........ ១៤
៣.៦ ខេត្តបន្ទាយមានជ័យ ........ ១៥
៤. ការគំរាមកំហែងព្រៃលិចទឹក ........ ១៥
៤.១ កំណើនប្រជាជន ........ ១៥
៤.២ ការរានព្រៃលិចទឹកដើម្បីធ្វើស្រែចំការ ........ ១៧
៤.៣ ការកាប់ធ្វើអុស និងធ្យូង ........ ២០
៤.៤ ការកាប់ព្រៃលិចទឹកធ្វើសំរាស់ និងឧបករណ៍នេសាទ ........ ២១
៤.៥ ភ្លើងឆេះព្រៃ ........ ២២
៤.៦ ការបំពុលទឹក ........ ២៣
៥. ប្រភេទសត្វដែលមាននៅក្នុងព្រៃលិចទឹក ........ ២៤
៥.១ ត្រី ........ ២៦
៥.២ សត្វឥតឆ្អឹងកង និងសត្វបាតបឹង ........ ២៦
៥.៣ ថនិកសត្វ ........ ២៧
៥.៤ សត្វស្លាប ........ ២៧





៥.៥ លូន ........ ២៨
៦. សន្និដ្ឋាន ........ ២៩
៧. ឯកសារយោង ........ ២៩

ឧបសម្ព័ន្ធទី១: បញ្ជីរាយនាមឈ្មោះរុក្ខជាតិដែលដុះនៅក្នុងតំបន់ព្រៃលិចទឹក ........ ៣១
ឧបសម្ព័ន្ធទី២: បញ្ជីរាយនាមឈ្មោះសត្វស្លាបទឹកសំខាន់ៗមួយចំនួន ........ ៣៣
ឧបសម្ព័ន្ធទី៣: បញ្ជីរាយនាមឈ្មោះត្រី ........ ៣៥
ឧបសម្ព័ន្ធទី៤: ស្ថានប្រព័ន្ធសំខាន់ៗនៅកម្ពុជា ........ ៣៩

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសមួយដែលសំបូរទៅដោយធនធានធម្មជាតិជាច្រើន ដែលក្នុងនោះមានដូចជា ធនធានក្នុងទឹក និងធនធានក្នុងដី និងនៅខាងលើ ដែលយើងអាចឃើញមានដូចជាព្រៃឈើ សត្វព្រៃ មច្ឆជាតិ និងបឹងបួរទន្លេជាច្រើនទៀត។ ចំពោះធនធានព្រៃឈើនៅកម្ពុជាគេបានបែងចែកជាប្រាំបួនថ្នាក់ ដែលក្នុងនោះគេឃើញព្រៃឈើម្យ៉ាង ដែលដុះនៅតាមបណ្តោយទន្លេមេគង្គ និងនៅតាមបឹងទន្លេសាប ដែលគេអោយឈ្មោះថា "**ព្រៃលិចទឹក**"។ ព្រៃលិចទឹកនៅកម្ពុជាមានដុះភាគច្រើននៅ បឹងទន្លេសាបដែលជាតំបន់ដីសើមដែលពោរពេញទៅដោយជីវិតជាច្រើនប្រភេទដែលរស់នៅក្នុងនោះជាពិសេស តំបន់ដែលមានព្រៃលិចទឹក។ តំបន់ព្រៃលិចទឹកផ្តល់លក្ខណៈល្អដល់ពូកមច្ឆាជាតិទាំងឡាយក្នុងការពងកូន និងជាកន្លែងរស់នៅ និងរកចំណីអាហារសំរាប់ចិញ្ចឹមជីវិត។ ដោយល្បឿនទឹកហូរនៅក្នុងតំបន់នេះមិនសូវខ្លាំង ជាហេតុធ្វើអោយមានកំទេចកំទីនៅទីនោះច្រើន កំទេចកំទីទាំងនោះហើយដែលជាប្រភពដំបូងនៃចំណីអាហាររបស់ភាវរស់នៅក្នុងតំបន់នេះ (ប្លង់តុងសត្វត្រី)។ កំទេចកំទីដែលទើរនៅទីនេះ ជាកត្តាមួយដែលជួយកាត់បន្ថយការចាក់ចោលកំទេចកំទីចូលទៅក្នុងបឹងទន្លេសាប ដែលធ្វើអោយបឹងកាន់តែរាក់មួយចំនួនធំ។ ព្រៃលិចទឹកក៏ដូចជាព្រៃងទៀតដែរគឺវាបានធ្វើខ្លួនវាជារនាំងការពារខ្យល់ព្យុះ និងបញ្ចេញ $O_2$ ដោយស្រូបយកនូវ $CO_2$ ពីបរិយាកាសហើយព្រៃលិចទឹកជាប្រភពថាមពលដ៏ចំបងសំរាប់ការចំអិនអាហាររបស់ប្រជាពលរដ្ឋម្យ៉ាងទៀតផ្លែកខ្លះនៃប្រភេទរុក្ខជាតិលិចទឹកមួយចំនួនអាចយកទៅធ្វើជាឱសថផ្សេងៗ ។



*តំហើញពីអាកាសនៃព្រៃលិចទឹកក្បែរបឹងទន្លេសាប (ETAP)*





អ្វីៗដែលព្រៃលិចទឹកផ្តល់អោយទាំងនេះបានជួយរួមចំណែកក្នុងការធ្វើអោយសេដ្ឋកិច្ចគ្រួសាររបស់ប្រជានេសាទក៏ដូចជាសេដ្ឋកិច្ចប្រទេសបានល្អប្រសើរដោយប្រជានេសាទអាចទាញផលពីព្រៃលិចទឹកបានដោយផ្ទាល់ ឬដោយប្រយោល ។

## ២ ប្រវត្តិព្រៃលិចទឹក

កម្ពុជាមានផ្ទៃព្រៃឈើគ្របដណ្តប់រហូតដល់ ៧៣% នៃផ្ទៃប្រទេសក្នុងនោះមាន ៥.១៥% ស្មើនឹង ៦៨១ ៤០០ ហិចតា ជាផ្ទៃព្រៃលិចទឹក (ប៉ាន លាងចេវ: ១៩៧២)។ បរិមាណនេះមានភាពខុសប្លែកគ្នាទៅនឹងទំហំព្រៃលិចនៅឆ្នាំ ១៩៧៣ ដែលត្រូវបានរៀបរៀងដោយ FAO ថាព្រៃលិចមានទំហំ ៩៣៧៩០០ ហិចតា។ បរិមាណដ៏ច្រើននេះមានដុះនៅភាគច្រើននៅជុំវិញបឹងទន្លេសាប ដែលជាកន្លែងមួយពោលពេញទៅដោយភោគទ្រព្យជីវៈចំរុះ ដែលភាពសំបូរនេះត្រូវបានគេទទួលស្គាល់ តាមរយៈព្រះរាជក្រឹត្យនៅឆ្នាំ ១៩៩៣ ស្តីពីការចាត់បឹងទន្លេសាបចូលទៅក្នុងតំបន់ការពារធម្មជាតិរបស់កម្ពុជា និងតាមរយៈអង្គការ យូណេស្កូ នៅឆ្នាំ១៩៩៨ ដែលគេចាត់ទុកជាមណ្ឌលជីវៈបំរុង។ ស្របពេលកម្ពុជាមានវិបត្តិសង្គ្រាមស៊ីវិលជាងពីរទស្សវត្សបានធ្វើអោយទំហំព្រៃលិចទឹកមានការថយចុះយ៉ាងខ្លាំង ដែលរហូតមកដល់ឆ្នាំ ១៩៩៩ នៅសល់ប្រហែល៣៥១ ២០៦ហិចតា (MRC:១៩៩៩)។ បរិមាណ នេះកំពុងតែទទួលរងនូវការគំរាមគំហែងដោយ តំរូវការរបស់ប្រជាជននៅក្នុង និងក្រៅ តំបន់មានការកើនឡើង។ ការបាត់បង់ព្រៃលិចទឹកភាគច្រើនកើតឡើងដោយការពង្រីកដីកសិកម្ម និងការធ្វើអាជីវកម្មលើព្រៃលិចទឹក នៅតាមតំបន់បឹងទន្លេសាប ។



*ព្រៃលិចទឹកបឹងទន្លេសាប នៅក្នុងកំឡុងរដូវវស្សា*

តារាងលេខ១: ស្ថិតិនៃការបាត់បង់ព្រៃលិចទឹកកម្ពុជាពីឆ្នាំ ១៩៦៤-១៩៩៧

( ទំហំ គិតជាហិចតា)

| ប្រភេទព្រៃលិចទឹក | ១៩៦៤[១] | ១៩៧៣[២] | ១៩៨៥[២] | ១៩៩៣[២] | ១៩៩២/៩៣[៣] | ១៩៩៦/៩៧[៣] | ១៩៩៧[៤] |
|---|---|---|---|---|---|---|---|
| ព្រៃលិចទឹក | ៦៨១៤០០ | ៩៣៧៩០០ | ៧៩៩៤០០ | ៣៧០៧០០ | ២២៩២៦៦ | ២១៩៩០៦ | ២២២១៥០ |
| ព្រៃលិចទឹកដុះដោយដុំ | | | | | ៩៨៥៨៧ | ៩៤៥៨២ | ១០៥៤៦៥ |
| ព្រៃលិចទឹកដុះឡើងវិញ | | | | | ២១៦២៣ | ២០៨១៩ | ២៣៥៩១ |
| ព្រៃគុម្ពោតលិចទឹក | | | ២៨២០០០ | ២៥៩៨០០ | ៣៧៧៤០១ | ៣៨៨៩៧១ | |

ប្រភព: CDIR, ២០០២

(១) Report No. 2 of Ministry of Water, Forest., and Hunting (1995) in Ung (1991).

(២) FAO (1994) in World Bank, UNDP, and FAO (1996).

(៣) MAFF in Chan et al, (2001).

(៤) Mekong River Commission Forest Cover Monitoring Project in World Bank (1999).







ទិដ្ឋភាពពីខាងលើ ព្រៃលិចទឹកនៅតំបន់បឹងឆ្មា ខេត្តកំពង់ធំ

## ៣ របាយព្រៃលិចទឹកនៅបឹងទន្លេសាប

ព្រៃលិចទឹកមានដុះនៅតាមតំបន់មាត់ បឹង តំបន់មាត់ទន្លេ ស្ទឹងព្រែក ដែលលិចទឹកនៅរដូវវស្សា រឺលិចទឹកអចិន្ត្រៃយ៍។ ព្រៃលិចទឹកដុះរាយប៉ាយពាសពេញគ្រប់ទឹកន្លែងនៅតំបន់ដែននេសាទ។ វិសាលភាពរបស់ព្រៃលិចទឹកមានការប្រែប្រួលទៅតាមរបបទឹកជំនន់នៃបឹងទន្លេសាប ដែលនៅខែឧសភា និងមិថុនាជារដូវទឹកហូរចូលបឹងទន្លេសាបបន្តអោយកំពស់ទឹកកាន់តែខ្ពស់នៅក្នុងខែកញ្ញា និងតុលា ហើយស្រកទៅវិញចាប់ពីខែតុលារហូតដល់ខែធ្នូ ដែលមានវិសាលភាពខ្លាំងនៅក្នុងរដូវវស្សាទឹកបឹងមានជំរៅ ៨-១០ ម៉ែត្រ (លិចព្រៃលិចទឹក) គ្របដណ្តប់លើផ្ទៃទឹក ១-១.៥ លានហិចតា និង

នៅរដូវប្រាំងជំរៅទឹកពី ១-១.៥ ម៉ែត្រ ដែលគ្របដណ្តប់ផ្ទៃទឹក ប្រហែល ២៥០០០០-៣០០០០០ ហិចតា។ សូមបញ្ជាក់ថា គេអាចសំគាល់ព្រៃលិចទឹក ដោយស្រទាប់ក្រោមសំបូរបែប មានឫសជន្ទល់ មានគ្រាប់ពូជអណ្តែតទឹក និងសាច់ឈើមានដង់ស៊ីតេទាប ដែលអនុញ្ញាត្តិអោយដើមឈើអណ្តែតទឹកបាន នៅពេលប្រាំងត្រូវប្រោះបាក់ ។



ព្រៃលិចទឹក ឬព្រៃលិចទឹកអចិន្ត្រៃយ៍បឹងទន្លេសាប

ការរាយប៉ាយព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាបត្រូវបានបែងចែកជាពីរប្រភេទធំៗគឺ ព្រៃលិចទឹកអចិន្ត្រៃយ៍ និងគុម្ពោតព្រៃលិចទឹក។ ព្រៃលិចទឹកអចិន្ត្រៃយ៍ រឺគេហៅថា ព្រៃលិចទឹក ដែលវាមានកំពស់ប្រហែល ៧-១៥ ម៉ែត្រ។ វាដុះមានលក្ខណ:លុបនៅក្នុងរដូវប្រាំងជាប់នឹងមាត់បឹងទន្លេសាបដែលគ្របដណ្តប់លើផ្ទៃប្រហែល ១០%នៃទំនាបលិចទឹក និងទំរង់ព្រៃបន្ទាប់។ ទំហំរបស់ព្រៃលិចទឹកនៅក្នុងឆ្នាំ ១៩៩២-៩៣ មានទំហំ ១៧៩ ១០៨ហិចតា ដែលមកដល់ឆ្នាំ១៩៩៦-៩៧ វាមានទំហំ ១៧៧ ៧៥១ ហិចតា ដែលទំហំនេះគ្របដណ្តប់លើខេត្តចំនួនប្រាំមួយ។ នៅក្នុងរដូវទឹកឡើង រយ:ពេល ៦ខែ ព្រៃលិចទឹកត្រូវលិចដោយទឹកកំពស់៤-៦ម៉ែត្រ ដែលកំឡុងពេលនោះប្រភេទសំខាន់ជំរុះស្លឹករបស់វា។ នៅក្នុងតំបន់នេះក៏មានប្រភេទឈើដែលដុះនៅក្នុងព្រៃគុម្ពោតលិចទឹកដែរ តែវាមានទ្រង់ទ្រាយធំ ហើយនៅទីនេះមានលក្ខណ:ជាព្រៃល្បោះដែលមានរុក្ខជាតិស្មៅអណ្តែតទឹក និងមានវល្លិឈើដទៃទៀតដូចជា: *Combretum trifoliatum (Combretaceae), Breynia rhamnoides (Euphorbiaceae), Tetracera sarmentosa (Dilleniaceae)*, និង *Acacia thailandica (Fabaceae-Minosoideae)*

ចំពោះប្រភេទគុម្ពោតព្រៃលិចទឹកជាប្រភេទព្រៃដែលដុះនៅជុំវិញបឹងទន្លេសាបដែលមានកំពស់ទាបៗ និងគ្របដណ្តប់៨០%នៃទំនាប





លិចទឹកបឹងទន្លេសាបដែលរុក្ខជាតិមួយចំនួនធំជាប្រភេទព្រៃពាក់កណ្តាលស្លឹកម្ជុលមានកំពស់មិនលើសពី ២-៤ ម៉ែត្រ (របាយការណ៍ស្តីពីស្ថានភាពជីវៈចំរុះនៅកម្ពុជា ២០០១)។ ទំហំរបស់គុម្ពោតព្រៃលិចទឹកនៅក្នុង ឆ្នាំ ១៩៩២-១៩៩៣ មានទំហំ ២៤៧ ៦៨៤ ហិចតា ហើយមកដល់ឆ្នាំ ១៩៩៦-១៩៩៧ វាមានទំហំ ២៤២ ១៥៥ ហិចតា ដែលទំហំនេះវាគ្របដណ្តប់លើខេត្តចំនួនប្រាំមួយ។ ប្រភេទលុបនៃប្រភេទរុក្ខជាតិក្នុងព្រៃគុម្ពោត ដើមឈើទាបៗមានដូចជាអំបូរ Euphorbiaceae, Fabacese និង Combretacese ( McDonald .et .al ១៩៩៧ ) ។

ព្រៃលិចទឹកនៅបឹងទន្លេសាបមានរុក្ខជាតិ



ព្រៃគុម្ពោតលិចទឹក

ច្រើនប្រភេទខុសៗគ្នា ដែលធ្វើអោយការលូតលាស់របស់ព្រៃលិចទឹកមានលក្ខណ:ខុសៗគ្នាទៅតាមប្រភេទរុក្ខជាតិ និងទៅតាមរដូវកាល។ នៅរដូវវស្សាព្រៃលិចទឹក ដែលលិចទាំងស្រុងដោយទឹកជំនន់មិនអាចលូតលាស់ទេ ព្រោះវាមិនបានទទួលពន្លឺព្រះអាទិត្យគ្រប់គ្រាន់ដើម្បី ធ្វើរស្មីសំយោគ។ ក្នុងដំណាក់នេះស្លឹករបស់រុក្ខជាតិជ្រុះអស់ ហើយអាចបន្តការរស់នៅបាន ៦-៧ ខែទៀត ហើយស្លឹកឈើទាំងនោះរលួយ ក្លាយទៅជាចំណីត្រី និងធ្វើអោយបរិស្ថាននៃព្រៃទាំងមូលមានជីវសាស្ត្រយ៉ាងច្រើន។ នៅក្នុងរដូវប្រាំងជារដូវលូតលាស់របស់ព្រៃលិចទឹកមានរយ:ពេល ៦ខែ ដោយវាទទួលបានពន្លឺគ្រប់គ្រាន់។ ដោយការធ្វើរស្មីសំយោគព្រៃចាប់ផ្តើមលូតលាស់ដុះពន្លក ស្លឹក ឫស បន្តការលូតលាស់ទៅមុខទៀត ។

ការលូតលាស់របស់ព្រៃលិចទឹកមានបីរបៀបគឺ:

- ការលូតលាស់ដោយគ្រាប់ (ការដុះគ្រាប់ពូជ)
- ការលូតលាស់បន្តពីដើមចាស់ (លិចនៅរដូវវស្សាហើយ ដុះឡើងវិញ)
- ការលូតលាស់ដោយគល់មួយចំនួន

ដែលប្រជាជនបានកាប់ដើម ។

ព្រៃលិចទឹកនៅតំបន់នេះគេចាត់ថ្នាក់ជាបួនគឺ ព្រៃលិចទឹកដុះឡើងវិញ ព្រៃលិចទឹកដុះដោយដុំព្រៃលិចទឹក និងព្រៃគុម្ពោតលិចទឹក ដែលប្រភេទទាំងអស់នេះមានដុះក្នុងបណ្តាខេត្តជាប់បឹងទន្លេសាប។ តារាងខាងក្រោមទាំងពីរនេះ បង្ហាញអំពីស្ថិតិព្រៃលិចទឹកនៅក្នុងឆ្នាំ ១៩៩២-៩៣ និងរវាងឆ្នាំ ១៩៩៦-៩៧ ដែលមាននៅក្នុងខេត្តជាប់បឹងទន្លេសាបទាំងប្រាំមួយគឺ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប ។

## ៣.១ ខេត្តសៀមរាប

ខេត្តសៀមរាបមានព្រំប្រទល់ជាប់បឹងទន្លេសាបប្រវែង ៨២ គម ដែលស្ថិតនៅជាប់ស្រុកជីក្រែង ស្រុកសូត្រនិគម ស្រុកសៀមរាប ស្រុកពួក ស្រុកក្រឡាញ់ និងស្រុកប្រាសាទបាគង។ ក្នុងស្រុកខាងលើនេះមានឃុំសរុប ៦៧

តារាងលេខ២: ស្ថិតិព្រៃលិចទឹកនៅបណ្តាខេត្តជាប់បឹងទន្លេសាបឆ្នាំ១៩៩២-១៩៩៣

| ប្រភេទព្រៃឈើ | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ធំ | ពោធិ៍សាត់ | សៀមរាប |
|---|---|---|---|---|---|---|
| | Area (ha) | | | | | |
| ព្រៃលិចទឹកដុះឡើងវិញ | 0 | ៨ ៦០៧ | 0 | ៥២ | ១២ ៥២៣ | 0 |
| ព្រៃលិចទឹក | ២៦ | ៦១ ១៧៣ | ១៥ ៧៥៧ | ៥៥ ៤១៥ | ២២ ៦៥០ | ១៧ ០០៤ |
| ព្រៃលិចទឹកដុះដោយដុំ | 0 | ៣៥ ៣៤១ | ៦៥១ | ៥ ០៣៣ | ១៤ ២១០ | ២៤ ១០៦ |
| ព្រៃគុម្ពោតលិចទឹក | ៦ ៣៧៤ | ៧៥ ០៤៥ | ៦៥ ៤៧៧ | ១៦ ៥២០ | ២៦ ៧៦៦ | ៥៣ ១៦៣ |

ប្រភព: ស្ថិតិសំយោគព្រៃឈើកម្ពុជាត្រឹមឆ្នាំ ២០០២, នាយកដ្ឋានព្រៃឈើ ប្រមាញ់





ដែលមានឃុំចំនួន៣៩ ស្ថិតនៅលើតំបន់ទំនាបកណ្តាល និងតំបន់លិចទឹក។ សៀមរាបសំបូរទៅ

តារាងលេខ៣: ស្ថិតិព្រៃលិចទឹកនៅបណ្តាខេត្តជាប់បឹងទន្លេសាបឆ្នាំ១៩៩៦-១៩៩៧

| ប្រភេទព្រៃឈើ | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ធំ | ពោធិ៍សាត់ | សៀមរាប |
|---|---|---|---|---|---|---|
| | Area (ha) | | | | | |
| ព្រៃលិចទឹកដុះឡើងវិញ | 0 | ៧ ៩០២ | 0 | ៥២ | ១២ ៥២៣ | 0 |
| ព្រៃលិចទឹក | ២៦ | ៦១ ១៧៣ | ១៥ ៧៥៧ | ៥៥ ៤១៥ | ២២ ៥៦០ | ១៥ ៦៥៧ |
| ព្រៃលិចទឹកដុះដោយដុំ | 0 | ៣៥ ៩០៥ | ៦៥១ | ៥ ០៣៣ | ១៣ ៥៥៣ | ២៣ ៣៥៦ |
| ព្រៃគុម្ពោតលិចទឹក | ៦ ៣៧៤ | ៧៧ ០៤៥ | ៦៣ ៥១៤ | ១៦ ៩០២ | ២៦ ២៣១ | ៥១ ៧៥៥ |

ប្រភព: ស្ថិតិសំយោគព្រៃឈើកម្ពុជាត្រឹមឆ្នាំ ២០០២, នាយកដ្ឋានព្រៃឈើ ប្រមាញ់

ដោយស្ទឹង បឹងបួរ ប្រឡាយជាច្រើនក្នុងនោះមានស្ទឹងក្រឡាញ់ ស្ទឹងសៀមរាប ស្ទឹងឆ្លងរលួស ស្ទឹងជីក្រែង ដែលមានប្រភពទឹកនៅតំបន់ខ្ពង់រាប ហើយហូរចាក់ចូលបឹងទន្លេសាប។ នៅលើផ្ទៃដីព្រៃលិចទឹកដែលសល់ប្រហែល ៩៤ ២៧៣ ហិចតា (ក្រសួងកសិកម្ម : ២០០៣) គ្របដណ្តប់លើស្រុក ដែលជាប់បឹងទន្លេសាប និងស្ទឹងខាងលើ ដែលសព្វថ្ងៃនេះបាននឹងកំពុងទទួលរងនូវការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរពីសំណាក់ប្រជាជននៅក្នុង និងក្រៅតំបន់នេះទៅលើព្រៃលិចទឹក ។



ព្រៃលិចទឹកនៅចុងឃ្នៀស សៀមរាប



*ព្រៃលិចទឹកក្បែរក្រុងសៀមរាប*

សកម្មភាពបំផ្លាញព្រៃលិចទឹកដោយផ្ទាល់មានដូចជាការកាប់ឆ្ការធ្វើចំការសណ្តែក ធ្វើស្រែប្រាំង ចំការឈូក ដុតព្រៃលិចទឹកចាប់សត្វ និងការកាប់ឈើព្រៃលិចទឹកសំរាប់ការប្រើប្រាស់ផ្សេងៗ។ ចាប់ពីឆ្នាំ១៩៨៥ រហូតដល់ ឆ្នាំ២០០០ មានប្រជាជនមកពីឃុំសៀមរាប ឃុំជ្រាវ ឃុំសំបូរ និងស្វាយដង្គុំ បានកាប់ និងដុតព្រៃលិចទឹកធ្វើស្រែប្រាំងអស់ប្រមាណ ១៤០០ ហិចតា។ ហើយនៅចន្លោះឆ្នាំ ១៩៨៦-២០០០ ដី ចំការឈូកត្រូវបានពង្រីកប្រមាណ ៣៧៥ ហិចតាទៀតសំរាប់ការដាំឈូកជាលក្ខណៈឯកជន។ ក្រៅពីសកម្មភាពបំផ្លាញព្រៃលិចទឹកដោយផ្ទាល់ទាំងនេះ នៅមានការបំផ្លាញដោយប្រយោលទៀតដូចជា ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតដោយមានបរិមាណលើសលប់ និងមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលថ្នាំទាំងនោះមានដូចជា DDT, Pholidor (ប្រភេទហាមឃាត់ដាច់ខាត) ត្រូវបានប្រើប្រាស់លើដំណាំឈូកជាមធ្យម ២,៨ គក/ហិចតាក្នុងមួយរដូវ។ ថ្នាំពុលទាំងនេះហូរចូលបឹងទន្លេសាប នាំអោយប៉ះពាល់ដល់ការលូតលាស់របស់ព្រៃលិចទឹក ។

### ៣.២ ខេត្តបាត់ដំបង

បាត់ដំបងជាខេត្តមួយជាប់បឹងទន្លេសាបដែលមានព្រំប្រទល់ប្រវែង ៣០ គម ជាប់បឹងទន្លេសាបស្ថិតនៅលើស្រុកពីរ គឺស្រុកឯកភ្នំ និងស្រុកសង្កែ នៅក្នុងស្រុកទាំងពីរនេះមានឃុំជាប់បឹងទន្លេសាបដូចជា ឃុំកោះជីវាំង ព្រៃចាស់ ព្រែកនិរិន្ទ ព្រែកខ្ពប ព្រែកហ្លួង ពាមឯក និងឃុំតាប៉ុនរបស់ស្រុកសង្កែ។ នៅក្នុងខេត្តមានស្ទឹងជាច្រើនដូចជាស្ទឹងសង្កែ មង្គលបុរី បរិល មោង-ឫស្សី និងមានព្រែក បឹងបួរ ជាច្រើនទៀត។ នៅលើតំបន់ទាំងនេះមានដុះព្រៃលិចទឹក ដែលវាចាប់លាតសន្ធឹងលើព្រំប្រទល់វាលស្រែស្រូវឡើង







*ព្រៃលិចទឹកនៅតាមបណ្តោយស្ទឹងសង្កែ*

ទឹក នៃស្រុកថ្មគោល ឯកភ្នំ សង្កែ និងមោងឫស្សី រហូតដល់បឹងទន្លេសាប ។

តាមការស្រាវជ្រាវរបស់នាយកដ្ឋានជលផល ក្នុងឆ្នាំ១៩៩១-៩២ ជាមួយការិយាល័យជលផល បរិមាណព្រៃលិចទឹកដែលដុះពីមុនមាន២៣៧០០ ហិចតា។ ដោយសារការកាប់រានយកដីដាំដំណាំ ភ្លើងឆេះព្រៃ និងការដុតព្រៃ ដើម្បីចាប់សត្វរកឃ្មុំ និងដោយសារសង្គ្រាម បរិមាណព្រៃលិចទឹកមានការខូចខាត និងថយចុះជាលំដាប់ ។

### ៣.៣ ខេត្តកំពង់ឆ្នាំង

បឹងទន្លេសាបហូរកាត់ខេត្តកំពង់ឆ្នាំងមានប្រវែងប្រមាណ ១១០ គម ចាប់ពីព្រំប្រទល់ខាងត្បូងរបស់ខេត្តត្រង់ស្រុកកំពង់ត្រលាច និងឃុំលង្វែក ហូរកាត់តាមបណ្តោយព្រំប្រទល់ខាង

*តារាងលេខ៤: ស្ថិតិព្រៃលិចទឹកតាមបណ្តាឆ្នាំក្នុងខេត្តបាត់ដំបង*[៥]

| ទីតាំង | មុនឆ្នាំ១៩៩២ (ហ.ត) | ក្នុងឆ្នាំ១៩៩២ (ហ.ត) | ក្នុងឆ្នាំ២០០០ (ហ.ត) |
|---|---|---|---|
| ព្រៃលិចទឹកស្ថិតក្នុងនាទីឡូតិ៍នេសាទ | ១១១ ៧០០ | ៧៩ ២៣៧ | ៧១ ៥០០ |
| ព្រៃលិចទឹកស្ថិតក្រៅនាទីឡូតិ៍នេសាទ | ១២៦ ០០០ | ៨៨ ២០០ | ៨៧ ០០០ |
| សរុប | ២៣៧ ៧០០ | ១៦៧ ៤៣៧ | ១៥៨ ៥០០ |

*(ប្រភព: ការិយាល័យជលផល)*

(៥) ទិន្នន័យនេះមានការខុសគ្នាទៅនឹងទិន្នន័យរបស់ក្រសួងកសិកម្មឆ្នាំ២០០៣



ព្រៃលិចទឹកនៅតាមបណ្តោយស្ទឹងសង្កែ

ទឹក នៃស្រុកថ្មគោល ឯកភ្នំ សង្កែ និងមោងឫស្សី រហូតដល់បឹងទន្លេសាប ។

តាមការស្រាវជ្រាវរបស់នាយកដ្ឋានជលផល ក្នុងឆ្នាំ១៩៩១-៩២ ជាមួយការិយាល័យជលផល បរិមាណព្រៃលិចទឹកដែលដុះពីមុនមាន២៣៧០០ ហិចតា។ ដោយសារការកាប់រានយកដីដាំដំណាំ ភ្លើងឆេះព្រៃ និងការដុតព្រៃ ដើម្បីចាប់សត្វរកឃ្មុំ និងដោយសារសង្គ្រាម បរិមាណព្រៃលិចទឹកមានការខូចខាត និងថយចុះជាលំដាប់ ។

## ៣.៣ ខេត្តកំពង់ឆ្នាំង

បឹងទន្លេសាបហូរកាត់ខេត្តកំពង់ឆ្នាំងមានប្រវែងប្រមាណ ១១០ គម ចាប់ពីព្រំប្រទល់ខាងត្បូងរបស់ខេត្តត្រង់ស្រុកកំពង់ត្រលាច និងឃុំលង្វែក ហូរកាត់តាមបណ្តោយព្រំប្រទល់ខាង

*តារាងលេខ៤: ស្ថិតិព្រៃលិចទឹកតាមបណ្តាឆ្នាំក្នុងខេត្តបាត់ដំបង*[៥]

| ទីតាំង | មុនឆ្នាំ១៩៩២ (ហ.ត) | ក្នុងឆ្នាំ១៩៩២ (ហ.ត) | ក្នុងឆ្នាំ២០០០ (ហ.ត) |
|---|---|---|---|
| ព្រៃលិចទឹកស្ថិតក្នុងនាទីឡូតិ៍នេសាទ | ១១១ ៧០០ | ៧៩ ២៣៧ | ៧១ ៥០០ |
| ព្រៃលិចទឹកស្ថិតក្រៅនាទីឡូតិ៍នេសាទ | ១២៦ ០០០ | ៨៨ ២០០ | ៨៧ ០០០ |
| សរុប | ២៣៧ ៧០០ | ១៦៧ ៤៣៧ | ១៥៨ ៥០០ |

*(ប្រភព: ការិយាល័យជលផល)*

[៥] ទិន្នន័យនេះមានការខុសគ្នាទៅនឹងទិន្នន័យរបស់ក្រសួងកសិកម្មឆ្នាំ២០០៣





កើត របស់ខេត្តកណ្តាល ត្រង់ស្រុករលាប្អៀរ ហើយបន្តហូរពីទីរួមខេត្ត ដល់ឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ជិតព្រំប្រទល់ខេត្តពោធិ៍សាត់ ។

ខេត្តមានស្រុកចំនួន៦ដែលនៅជាប់បឹងទន្លេសាប ដូចជាស្រុក បរិបូរណ៍ រលាប្អៀរជលគិរី កំពង់ត្រលាច កំពង់ឆ្នាំង និងស្រុកទឹកផុស ក្រៅពីនេះខេត្តនៅមានដៃរបស់បឹងទន្លេសាបជាច្រើនទៀតដូចជា ស្ទឹងក្រាំងពន្លៃ គង្គា បរិបូរណ៍ ។ ព្រៃលិចទឹកច្រើនដុះនៅតាមតំបន់ទំនាបលិចទឹករបស់ខេត្ត ដែលស្ថិតក្នុងស្រុកទាំង៦ និងតាមដងស្ទឹងនានា ។

តាមរយៈការវាស់នៅឆ្នាំ ១៩៩២-៩៣ បានបង្ហាញថា មានព្រៃលិចទឹក ៧២២ គ.ម$^2$ ស្មើ ៣៣.១២% ព្រៃលិចទឹកប្រភេទទីពី ១០៧ គ.ម$^2$ ត្រូវជា ៤.៤៩% នៃផ្ទៃព្រៃឈើក្នុងខេត្ត (Mekong Secretariat ១៩៩៤) ។ មុនពេលសង្គ្រាម (មុនឆ្នាំ ១៩៧០) ព្រៃលិចទឹក នៅក្នុងខេត្តនេះគ្របដណ្តប់លើផ្ទៃដី ៦០០០០ ហិចតា។ សព្វថ្ងៃនេះព្រៃលិចទឹក



ព្រៃលិចទឹកនៅតាមមាត់ព្រែកយួន ស្រុកជលគិរី

កំពុងតែរងការបំផ្លិចបំផ្លាញជាបន្តបន្ទាប់ ទាំងនៅក្នុង និងក្រៅតំបន់នេសាទ។ ឡូតិ៍ដែលមានការបំផ្លិចបំផ្លាញព្រៃលិចទឹកច្រើនមាន ឡូតិ៍លេខ២ លេខ៥ លេខ៨ ស្ថិតនៅស្រុកកំពង់លែង ឡូតិ៍លេខ១១ លេខ១២ លេខ១៣ លេខ១៤ ស្ថិតនៅស្រុក រលាប្អៀរ និងជលគិរី ចំណែកឯឡូតិ៍ដែលមិនសូវមានការបំផ្លិចបំផ្លាញមានឡូតិ៍លេខ១ មានព្រៃលិចទឹក ៥២៣២ ហិចតា (៥២.៣២ គម$^2$) ស្ថិតនៅស្រុកកំពង់លែង និងឡូតិ៍លេខ១០ មានផ្ទៃ ១៣ ៤៣៨ ហិចតា (១៣៤.៣៨ គម$^2$) ស្ថិតនៅស្រុកជលគិរី និងកំពង់លែងជាប់ព្រំប្រទល់ខេត្តកំពង់ចាម

កើត របស់ខេត្តកណ្តាល ត្រង់ស្រុករលាប្អៀរ ហើយបន្តហូរពីទីរួមខេត្ត ដល់ឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ជិតព្រំប្រទល់ខេត្តពោធិ៍សាត់។

ខេត្តមានស្រុកចំនួន៦ដែលនៅជាប់បឹងទន្លេសាប ដូចជាស្រុក បរិបូរណ៍ រលាប្អៀរជលគីរី កំពង់ត្រលាច កំពង់ឆ្នាំង និងស្រុកទឹកផុស ក្រៅពីនេះខេត្តនៅមានដៃរបស់បឹងទន្លេសាបជាច្រើនទៀតដូចជា ស្ទឹងក្រាំងពន្លៃ គង្គា បរិបូរណ៍។ ព្រៃលិចទឹកច្រើនដុះនៅតាមតំបន់ទំនាបលិចទឹករបស់ខេត្ត ដែលស្ថិតក្នុងស្រុកទាំង៦ និងតាមដងស្ទឹងនានា ។

តាមរយៈការវាស់នៅឆ្នាំ ១៩៩២-៩៣ បានបង្ហាញថា មានព្រៃលិចទឹក ៧២២ គ.ម² ស្មើ ៣៣.១២% ព្រៃលិចទឹកប្រភេទទីពី ១០៧ គ.ម² ត្រូវជា ៤.៩៥% នៃផ្ទៃព្រៃឈើក្នុងខេត្ត (Mekong Secretariat ១៩៩៤) ។ មុនពេលសង្គ្រាម (មុនឆ្នាំ ១៩៧០) ព្រៃលិចទឹក នៅក្នុងខេត្តនេះគ្របដណ្តប់លើផ្ទៃដី ៦០០០០ ហិចតា។ សព្វថ្ងៃនេះព្រៃលិចទឹកកំពុងតែរងការបំផ្លិចបំផ្លាញជាបន្តបន្ទាប់ ទាំងនៅក្នុង និងក្រៅតំបន់នេសាទ។ ឡូតិ៍ដែលមានការបំផ្លិចបំផ្លាញព្រៃលិចទឹកច្រើនមាន ឡូតិ៍លេខ២ លេខ៥ លេខ៨ ស្ថិតនៅស្រុកកំពង់លែង ឡូតិ៍លេខ១១ លេខ១២ លេខ១៣ លេខ១៤ ស្ថិតនៅស្រុក រលាប្អៀរ និងជលគីរី ចំណែកឯឡូតិ៍ដែលមិនសូវមានការបំផ្លិចបំផ្លាញមានឡូតិ៍លេខ១ មានព្រៃលិចទឹក ៥២៣២ ហិចតា (៥២.៣២ គម²) ស្ថិតនៅស្រុកកំពង់លែង និងឡូតិ៍លេខ១០ មានផ្ទៃ ១៣ ៤៣៨ ហិចតា (១៣៤.៣៨ គម²) ស្ថិតនៅស្រុកជលគីរី និងកំពង់លែងជាប់ព្រំប្រទល់ខេត្តកំពង់ចាម



ព្រៃលិចទឹកនៅតាមមាត់ព្រែកយួន ស្រុកជលគីរី







ព្រៃលិចទឹកក្នុងខេត្តពោធិ៍សាត់

និងកំពង់ធំ ។

យោងទៅតាមក្រសួងកសិកម្ម ស្តីពីការកំរិតព្រំដែនព្រៃលិចទឹកនៅឆ្នាំ ១៩៩២ បានបង្ហាញថាព្រៃលិចទឹក នៅឡូតិ៍លេខ១២ រងការកាប់បំផ្លាញអស់ ១៣ ១១៤ ហិចតា សំរាប់ឡូតិ៍ដទៃទៀតមិនមានពតិមានទេ ។

ចំណែកឯរបាយការណ៍ក្រសួងកសិកម្ម បានបង្ហាញថាព្រៃលិចទឹកក្នុងខេត្តនៅចន្លោះឆ្នាំ ១៩៩៦-៩៧ មានផ្ទៃក្រឡាប្រហែល ៨៤ ៤០២ ហិចតា។ ហើយស្របពេលជាមួយគ្នានេះដែរ មានប្រជាជនជាច្រើនបាននាំគ្នាមករស់នៅក្នុងតំបន់នេះដើម្បីប្រកបរបរអាជីវកម្ម ជាពិសេសការធ្វើកសិកម្ម។ ក្នុងការបានដីកសិកម្ម ប្រជាជនបានរានដីព្រៃលិចទឹកយកមកធ្វើដីកសិកម្ម។ ប្រជាជនបំលាស់ទីចូលតំបន់នេះភាគច្រើនមកពីតំបន់ដែលនៅជិតតំបន់បឹងទន្លេសាបដូចជាខេត្តកំពង់ធំ កំពង់ចាម ...។

## ៣.៤ ខេត្តពោធិ៍សាត់

បឹងទន្លេសាបហូរកាត់ខេត្តពោធិ៍សាត់ ប្រមាណ ១៨១ គ.ម ហើយមានស្រុកបី ជាប់ព្រំប្រទល់បឹងទន្លេសាបគឺ ស្រុកកណ្តៀង បាកានក្រគរ។ ខេត្តពោធិ៍សាត់មានឃុំចំនួន ១៣ នៅ

ក្នុងស្រុកខាងលើជាប់បឹងទន្លេសាប ដូចជាឃុំរាំងទិល, ឃុំស្រែស្តុក, ឃុំកញ្ជរ, ឃុំស្យា នៅក្នុងស្រុកកណ្តៀង ឃុំបឹងបត់កណ្តាល, ឃុំមេទឹក, ឃុំស្នាមព្រះ, ឃុំអូរតាប៉ោង នៅក្នុងស្រុកបាកាន និងឃុំអូរសណ្តាន់, ឃុំកំពង់ពោធិ៍, ឃុំស្នាអន្សា, ឃុំកំពង់លួង, ឃុំអន្សាចំបក់, ឃុំក្បាលត្រាច នៅក្នុងស្រុកក្រគរ។ ពោធិ៍សាត់ នៅមានស្ទឹងហូរចូលបឹងទន្លេសាបដូចជា ស្ទឹងពោធិ៍សាត់ ស្ទឹងកំពង់ឡា និងស្ទឹងក្រគរ។ នៅតាមតំបន់ដែលជាប់បឹងទន្លេសាបនេះមានដុះនូវព្រៃលិចទឹកជាច្រើន ជាពិសេសនៅដែននេសាទ ឬឡូតិ៍នេសាទ ដែលព្រៃលិចទឹកគ្រប់ប្រភេទទាំងអស់គ្របដណ្តប់នៅក្នុងតំបន់នេះមានចំនួនសរុបទាំងអស់ប្រហែល ៧៦ ០០០ហិចតា នៅឆ្នាំ ១៩៩៦-៩៧ ដែលចំនួននេះមានការថយចុះអស់ ប្រហែល ៦០០ហិចតា ពីកំឡុងឆ្នាំ១៩៩២-៩៣ (ក្រសួងកសិកម្ម: ២០០៣)។

តាមរបាយការណ៍របស់មន្ទីរជលផលខេត្ត ដែលធ្វើការស្រាវជ្រាវនៅអំឡុងឆ្នាំ ១៩៩២ បានអោយដឹងថា នៅតំបន់ផ្លូវកំពង់ស្ទឹង និងក្រចាប់មានការកាប់បំផ្លាញព្រៃលិចទឹក ក្លាយជាវាលចំនួនបី។ វាលចំនួនពីរស្ថិតនៅផ្លូវ កំពង់ស្ទឹងមាន



ទិដ្ឋភាពព្រៃលិចទឹក ខេត្តពោធិ៍សាត់





ចំងាយប្រហែលតែ ២០០ម៉ែត ប៉ុណ្ណោះពីបឹងទន្លេសាប ដែលវាលទីមួយអស់ផ្ទៃដី ៤០ ហិចតា វាលទីពីរអស់ ៧៥ ហិចតា ចំណែកឯវាលមួយទៀតស្ថិតជិតផ្លូវជាតិត្រង់តំបន់ក្រចាប់ អស់ ៦៧ ហិចតា។ ភាគច្រើននៃផ្ទៃដីទាំងអស់នេះត្រូវបានគេកាប់ឆ្ការធ្វើដីកសិកម្ម។ តាមរយៈការសំភាសន៍ជាមួយមេឃុំ គាត់បានមានប្រសាសន៍ថា ផ្ទៃដីព្រៃលិចទឹកប្រហែលជា ២០% (៤៣ ហិចតា) នៅក្នុងឃុំត្រូវបានគេកាប់ចន្លោះឆ្នាំ ១៩៨៨-១៩៩០។ ការកាប់បំផ្លាញព្រៃលិចទឹកកើតមាននៅក្នុងឡូតិ៍លេខ៦ លេខ៣ ត្រង់ចំណុច បឹងអូក និងបឹងព្នៅ ឡូតិ៍លេខ៤ ចន្លោះបឹងសាឡិច និងបឹងឡាក់ ឡូតិ៍លេខ៥ នៅបឹងរាមកេ្ដី និងបឹងបូស ដែលស្ថិតនៅ ១ គ.ម ពីបឹងទន្លេសាប ឡូតិ៍លេខ១ ពីវាលបេផេនទៅចុងព្រៃក្រាល និងចុងតាលែនស្ថិតនៅ ២គ.ម ពីបឹងទន្លេសាប។ ឡូតិ៍លេខ២ ព្រៃលិចទឹកយ៉ាងច្រើនត្រូវបានដុត និងកាប់ឆ្ការសំរាប់ដីកសិកម្ម ដែលឥឡូវនេះនៅសល់ប្រហែលតែ ១ គ.ម ប៉ុណ្ណោះពីបឹងទន្លេសាប។ ចំណែកឯឡូតិ៍លេខ៦ និងលេខ៧ ក៏មានការកាប់យ៉ាងខ្លាំងក្លាដែរ ។

## ៣.៥ ខេត្តកំពង់ធំ

កំពង់ធំមានស្រុកចំនួនពីរជាប់បឹងទន្លេសាប ស្រុកស្ទោង និងស្រុកកំពង់ស្វាយ។ ហើយខេត្តនៅមានប្រព័ន្ធផ្លូវទឹក ជាច្រើនទៀតជាពិសេសស្ទឹងដែលនៅជាប់បឹងទន្លេសាបដូចជាស្ទឹងសែន ស្ទឹងស្ទោង ស្ទឹងជីនិត និងស្ទឹងជីក្រែង។ នៅតាមមាត់ស្ទឹង និងតាមតំបន់ទំនាបលិចទឹករបស់ខេត្តមានដុះនូវព្រៃលិចទឹកជាច្រើន តែបរិមាណព្រៃលិចទឹកមានការថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ នៅកំឡុងឆ្នាំ១៩៨៥/៨៧ ព្រៃលិចទឹកមានទំហំ ១០៩ ៣០០ ហិចតា តែបរិមាណនេះមានការថយចុះយ៉ាងខ្លាំងមកដល់កំឡុងឆ្នាំ ១៩៩២-៩៣ នៅសល់តែ ៨៤៣៥៣ ហិចតា ហើយចេះតែថយចុះជាលំដាប់ ដែលនៅឆ្នាំ ១៩៩៦-៩៧ មានទំហំ ៨៤ ៣៣៥ ហិចតា ។



ព្រៃលិចទឹកតាមបណ្តោយស្ទឹងសែន កំពង់ធំ

### ៣.៦ ខេត្តបន្ទាយមានជ័យ

ព្រៃលិចទឹកនៅក្នុងខេត្តបន្ទាយមានជ័យ មានបរិមាណតិចជាងគេបើប្រៀបធៀបទៅនឹងបណ្តាខេត្តដែលនៅជាប់បឹងទន្លេសាប ដោយសារតែខេត្តនេះមិននៅជាប់បឹងទន្លេសាបទេ ប៉ុន្តែខេត្តនេះមានប្រព័ន្ធផ្លូវទឹកទាក់ទងនឹងបឹងទន្លេសាប ស្ថិតនៅកណ្តាលតំបន់ទំនាបបឹងទន្លេសាប។ ព្រៃលិចទឹកទាំងនេះមានដុះនៅតាមតំបន់ទំនាបរបស់ខេត្ត។ ព្រៃលិចទឹករបស់ខេត្តនៅឆ្នាំ ១៩៩៦-៩៧ មានទំហំ ៦៤០០ហិចតា (ក្រសួងកសិកម្ម: ២០០៣) ដែលទំហំនេះកំពុងតែទទួលរងនូវការគំរាមគំហែងពីការរានដីដើម្បីកសិកម្ម ដុតព្រៃចាប់សត្វ...។ ជាក់ស្តែងនៅក្នុងតំបន់បឹងក៏មានការដុតព្រៃលិចទឹកដើម្បីចាប់សត្វ (អណ្តើក អន្សង) ដែលការដុតនេះបានបំផ្លាញអស់ព្រៃចំនួន ៥ ហិចតា ។

## ៤ ការគំរាមគំហែងព្រៃលិចទឹក

### ៤.១ កំណើនប្រជាជន



ភូមិអណ្តែតទឹកនៅតាម បឹងទន្លេសាបក្នុងខេត្ត កំពង់ឆ្នាំង





ប្រទេសកម្ពុជាមានប្រជាជនសរុបចំនួន ១១.៤៣ លាននាក់ ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំ២.៤ ភាគរយ (ជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ១៩៩៨)។ យោងតាមការបោះពុម្ពផ្សាយរបស់ការិយាល័យចំនួនប្រជាជនពិភពលោកបានប៉ាន់ប្រមាណថា នៅឆ្នាំ ២០១០ កម្ពុជាមានប្រជាជន ១៥.៧ លាននាក់ ហើយចំនួននេះនឹងកើនឡើងដល់ ២២.៨ លាននាក់នៅឆ្នាំ ២០២៥។ តំបន់បឹងទន្លេសាបមានប្រជាជន ២៩.៨៥ ភាគរយ (៣ ៤១៤ ២៦៣ នាក់) នៃចំនួនប្រជាជនសរុប។ ម្យ៉ាងទៀតនៅតំបន់នេះមានចំនួនប្រជាជនក្រីក្រជាងគេនៅទូទាំងប្រទេស (៣៨ ភាគរយនៅក្រោមបន្ទាត់ក្រីក្រ ADB, ២០០២)។ កំណើនប្រជាជននេះមានន័យថាតំរូវការធនធានទាក់កើនឡើងដែរដូចជា ត្រី សាច់ ធញ្ញជាតិ ឈើ បន្លែ។ល។ ដើម្បីរកចំណីអាហារទាំងនេះគេត្រូវការចាំបាច់នូវ ដីដាំដំណាំ មានជីវជាតិ វាលស្មៅចិញ្ចឹមសត្វ ដែនទេសាទ និងអ្វីផ្សេងៗជាច្រើនទៀត។ ប្រជាជនកម្ពុជាជាច្រើនត្រូវការអុសដើម្បីចំអិនអាហារ។ សំរាប់ប្រជាពលរដ្ឋដែលរស់នៅតាមបឹងទន្លេសាប គេទាញយកផលប្រយោជន៍ទាំងអស់នេះពីបឹងទន្លេសាបជាពិសេសនោះ គឺព្រៃលិចទឹកវាផ្តល់ផលប្រយោជន៍ច្រើន។ ទាំងនេះជាមូលហេតុមួយនៃការគំរាមគំហែងធនធានព្រៃលិចទឹកឈានទៅរកការបាត់បង់ទៅថ្ងៃអនាគត ។

តារាងលេខ៥: ស្ថិតិប្រជាជននៅតាមបណ្តោយខេត្តជាប់បឹងទន្លេសាប

| ខេត្ត | ចំនួនប្រជាជន | ប្រុស | ស្រី | ភាគរយ |
|---|---|---|---|---|
| បន្ទាយមានជ័យ | ៥៧៧ ៧៧២ | ២៨៣ ៣៥៨ | ២៩៤ ៤១៤ | ៥.០៥ |
| បាត់ដំបង | ៧៩៣ ១២៩ | ៣៨៨ ៥៩៩ | ៤០៤ ៥៣០ | ៦.៩៣ |
| កំពង់ឆ្នាំង | ៤១៧ ៦៩៣ | ១៩៧ ៦៩១ | ២២០ ០០២ | ៣.៦៥ |
| កំពង់ធំ | ៥៦៩ ០៦០ | ២៧២ ៨៤៤ | ២៩៦ ២១៦ | ៤.៩៨ |
| ពោធិ៍សាត់ | ៣៦០ ៤៤៥ | ១៧២ ៨៩០ | ១៨៧ ៥៥៥ | ៣.១៥ |
| សៀមរាប | ៦៩៦ ១៦៤ | ៣៣៦ ៦៨៥ | ៣៥៩ ៤៧៩ | ៦.០៣ |

(ប្រភព: ជំរឿនប្រជាសាស្ត្រកម្ពុជា ឆ្នាំ ១៩៩៨)

ក្រៅពីជួយទប់ទល់នឹងគ្រោះថ្នាក់ធម្មជាតិ បង្កើនផលត្រី និងធ្វើអោយធម្មជាតិស្រស់ស្អាត នោះឈើរបស់ព្រៃលិចទឹក ត្រូវបានប្រជាជនយកមកប្រើប្រាស់ផ្សេងៗដូចជា សំភារៈ សំណង់ សំរាស់ អុស ធ្យូង ឱសថ។ ការដែលប្រជាជនយកឈើព្រៃលិចយកមកប្រើប្រាស់ផ្សេងៗអាចជួយកាត់បន្ថយការចំណាយរបស់គាត់មួយចំនួនធំទៅលើការទិញរបស់របរទាំងនេះ ហើយពួកគាត់

ព្រៃលិចទឹកជាកន្លែងមួយដ៏ល្អសំរាប់វិស័យទេសចរណ៍ ក្នុងការធ្វើដំណើរកំសាន្តតាមផ្លូវទឹក ការស្ទូចត្រីកំសាន្ត ព្រោះតំបន់នេះមានអាកាសធាតុល្អ និងសំបូរមច្ឆា និងសត្វព្រៃផ្សេងៗ ដែលទាក់ទាញអ្នកទេសចរណ៍ ។

ម្យ៉ាងទៀតព្រៃលិចទឹកសំបូរទៅដោយសត្វព្រៃ សត្វស្លាបផ្សេងៗ ដោយពួកវាអាចយកផ្លែឈើព្រៃលិចទឹកជាអាហារ ហើយនិងអាចចាប់យកត្រីជាអាហារបានងាយ (សំបូរត្រី)។ ហើយសត្វទាំងនេះអាចយកព្រៃលិចទឹកជាជំរកដ៏ល្អ និងជាកន្លែងបន្តពូជ ដោយគេងាយនឹងគេចចេញពីការយាយីរបស់មនុស្ស និងសត្វសាហាវផ្សេងៗ ។



*ស្ថានភាពនៃការរស់របស់ប្រជាជនក្នុងតំបន់ព្រៃលិចទឹក*

អាចរកកំរៃបានពីព្រៃលិចទឹក ថែមទៀតតាមរយៈការលក់អុស ធ្យូង ឱសថ...។ ដែលទាំងនេះជួយលើកកំពស់សេដ្ឋកិច្ចជាតិបានមួយកំរិតតូច ។

## ៤.២ ការរានព្រៃលិចទឹកដើម្បីធ្វើស្រែចំការ

ជារៀងរាល់ឆ្នាំព្រៃលិចទឹកបញ្ចេញបរិមាណយ៉ាងច្រើននូវសារធាតុបៃតង និងសារធាតុសរីរាង្គដូចជា សំបក ឫស ផ្លែ មែក...។ សារធាតុ





*គំនូសបំព្រួញពីតួនាទីព្រៃលិចទឹកលើការថែរក្សាគុណភាពដី*




ប្រភព: *អ៊ូ សិទ្ធិរិទ្ធិ ១៩៩៦*

ទាំងនេះបានរលួយក្រោមឥទ្ធិពលនៃធម្មជាតិក្លាយទៅជាធាតុរ៉ែ (Ca, K, P, S, ...) ហើយក្រោមឥទ្ធិពលនៃអាកាសធាតុ និងការបំបែកដោយអតិសុខុមប្រាណបានធ្វើអោយធាតុរ៉ែទាំងនេះក្លាយទៅជាអំបិលខនិចសំរាប់រុក្ខជាតិលូតលាស់។ សារធាតុខនិចទាំងនេះ ដែលនៅសល់ពីការប្រើប្រាស់របស់រុក្ខជាតិនៅក្នុងតំបន់ បានទៅជួយរក្សាគុណភាពដីអោយល្អជាងមុន ដោយរក្សាអោយដីនៅខ្មៅមានជីជាតិជានិច្ច ។

ប្រជាជនកម្ពុជា ៨៥% ជាប្រជាកសិករដែលប្រកបរបរកសិកម្ម ដែលគេបានស្មានថាមានប្រហែល ១.២-១.៣ លានគ្រួសារ (ជំនួយស្មារតីបរិស្ថាន)។ អ្នកដែលរស់នៅតាមទំនាបទន្លេសាបភាគច្រើនជាអ្នកប្រកបរបរនេសាទ និងធ្វើស្រែចំការទៅតាមរបបទឹកទន្លេសាប (ទឹកឡើង ទឹកស្រក) ក្រៅពីការធ្វើស្រែចំការ



*ការរានព្រៃលិចទឹកយកដីមកធ្វើកសិកម្ម*



ព្រៃលិចទឹកត្រូវបានរានយកមកធ្វើចំការពោត

ពួកគាត់នៅមានដាំដំណាំផ្សេងៗទៀតដូចជា ពោត សណ្តែក ថ្នាំជក់ និងបន្លែបង្កាជាច្រើនមុខ ទៀតសំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ស្របពេលជាមួយនឹងការកើនឡើងនៃប្រជាជននៅក្នុងតំបន់មានអត្រាខ្ពស់ ហេតុនេះពួកគាត់មួយចំនួនត្រូវការកាប់ឆ្ការព្រៃលិចទឹកជាច្រើន ដើម្បីយកដីមកធ្វើដីកម្មសិទ្ធសំរាប់កសិកម្ម ដែលជាមូលហេតុធ្វើអោយព្រៃលិចទឹកថយចុះ ។

នៅក្នុងដែននេសាទរបស់សហគមន៍ ភូមិអន្លង់អក ឃុំកំពង់អុស ស្រុកជលគីរី ខេត្តកំពង់ឆ្នាំងមានការបំផ្លាញព្រៃលិចនៅតាមមាត់ព្រែកយួន ដោយការរានយកដីមកធ្វើចំការពោត អស់ប្រហែលពី ៤-៥ ហិចតា។ ព្រែកយួនជាកន្លែងប្រមូលផលនេសាទ ដែលថវិការពីផលនេសាទមួយចំនួនត្រូវបានយកមកកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់នេះតែដោយសារការបាត់បង់នូវព្រៃលិចជាកន្លែងពងកូនរបស់ត្រី ហេតុដូចនេះ ទិន្នផលត្រីនៅទីនេះនឹងមានការថយចុះ។ នាពេលអនាគត បើបន្តនូវការបាត់បង់ព្រៃលិចហាក់បីដូចជាការធ្លាក់ចុះសេដ្ឋកិច្ចនៅក្នុងតំបន់នេះដែរ។ នាពេលថ្មី (ឆ្នាំ២០០៣) នេះគេសង្កេតឃើញថាមានការកាប់បំផ្លាញព្រៃលិចទឹកយ៉ាង





ងនៅតាមមាត់ព្រែកដែលមានផ្ទៃប្រហែល ៤ ហិចតា ដែលការបំផ្លាញនេះធ្វើឡើងដោយ ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានដោយពុំបាន សុំសេចក្តីសំរេចចិត្ត ពីអាជ្ញាធរមូលដ្ឋាន ។

## ៤.៣ ការកាប់ធ្វើអុស និងធ្យូង

ប្រភពថាមពលសំរាប់ចំអិនអាហារសំរាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅជនបទ នោះគឺ **អុស និងធ្យូង** ដែលមានប្រភពមកពីព្រៃឈើ។ ប្រជាពលរដ្ឋនៅជនបទបានប្រើអុស អស់ ៥ លានតោន និងធ្យូង ៨ ០០០ តោនក្នុងមួយឆ្នាំ ដែលទាញយកពីធនធានព្រៃឈើទាំងស្រុង។



ការកាប់ព្រៃលិចទឹកយកទៅធ្វើអុស និងធ្យូង

ប្រជាពលរដ្ឋដែលរស់នៅតំបន់បឹងទន្លេសាប ស្ទើរតែទាំងអស់ពឹងពាក់ទៅលើព្រៃលិចទឹកជាថាមពលសំរាប់ការរស់នៅរបស់គេ។ ក្រៅពីការប្រើប្រាស់ប្រចាំថ្ងៃពួកគេនៅបានកាប់ព្រៃលិចទឹក ធ្វើអុស និងធ្យូង ដើម្បីលក់រកប្រាក់ចំណូលបន្ថែម។ ការប្រើប្រាស់អុសរបស់ប្រជាជននៅតំបន់បឹងទន្លេសាបមានអត្រាខ្ពស់ជាងការប្រើប្រាស់អុសនៅថ្នាក់ជាតិ ។

តារាងលេខ៦: ការប្រើប្រាស់ថាមពលសំរាប់ចំអិនអាហារ របស់ប្រជាជននៅតាមបណ្តាខេត្តជាប់បឹងទន្លេសាប( ភាគរយ)

| ខេត្ត | អុស | ធ្យូង | ប្រេងកាត | ហ្គាស | ផ្សេងៗ |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | ៩០.៦ | ៧.៦ | ១.០ | ០.៥ | ០.៣ |
| បាត់ដំបង | ៩២.៤ | ៤.៤ | ១.៦ | ០.៦ | ១.០ |
| កំពង់ឆ្នាំង | ៩៥.៨ | ១.៩ | ១.៨ | ០.៤ | ០.១ |
| កំពង់ធំ | ៩៥.៦ | ១.៧ | ២.៤ | ០.៣ | |
| ពោធិ៍សាត់ | ៩៤.៦ | ១.៩ | ២.៥ | ០.៦ | ០.១ |
| សៀមរាប | ៩៦.១ | ១.៤ | ២.១ | ០.៤ | |

( ប្រភព: ជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ ១៩៩៨)

ការកាប់ព្រៃលិចទឹកធ្វើអុសរបស់ប្រជាជននៅភូមិកោះជីវាំង ឃុំព្រៃចាស់ ស្រុកឯកភ្នំ ខេត្តបាត់ដំបងមានលក្ខណៈជាអាជីវកម្មនិងប្រើប្រាស់ជាលក្ខណៈគ្រួសារ។ នៅចន្លោះពីខែសីហាដល់ដើមខែមករាក្នុងមួយថ្ងៃសំរាប់ទូកមួយគេកាប់បានពី ២ម៉ែត្រ ទៅ ៣ម៉ែត្រ ចំហៀង (ខ្នាតម៉ែតចំហៀង ដែលប្រជាពលរដ្ឋភូមិនេះប្រើប្រាស់: ០.៣ម៉ែត្រ x ១ម៉ែត្រ x ១ម៉ែត្រ)។ សំរាប់ការប្រើប្រាស់ប្រចាំថ្ងៃក្នុងមួយគ្រួសារប្រើអុសអស់ប្រហែល២០ម៉ែត្រចំហៀងក្នុងមួយឆ្នាំ។ ឈ្មួញទិញអុសមកពីខេត្ត បាត់ដំបងក្នុងមួយជើង១មានពី ២-៣ ទូក ដែលទូកនិមួយ១មានចំណុះប្រហែល ២០ទៅ៣៥ម៉ែតចំហៀង។ ទូកឈ្មួញដែលចុះទៅទិញអុសក្នុងភូមិនេះមានប្រហែល ២០-២៥ ទូកក្នុងមួយរដូវ ។



*ការកាប់ព្រៃលិចទឹកយកទៅធ្វើសំរាស់ក្នុង ខេត្តបាត់ដំបង*

## ៤.៤ ការកាប់ព្រៃលិចទឹក ធ្វើសំរាស់ និងឧបករណ៍នេសាទ

ប្រជាពលរដ្ឋដែលប្រកបរបរនេសាទ បាន ប្រើប្រាស់ព្រៃលិចទឹកធ្វើជាសំរាស់ដាក់ក្នុងទឹក សំរាប់ ចាប់ត្រី។ សំរាស់ត្រូវ ការព្រៃលិចទឹក ច្រើនរៀបគរ១គ្នាជាច្រើនជាន់សំរាប់អោយត្រី មកជ្រក(ត្រីកុំ) ដើម្បីប្រមូលយកផលអោយ បានច្រើន។ ការធ្វើឡូតិ៍នេសាទក៏ត្រូវការកាប់ ព្រៃលិចទឹកជាច្រើនដែរយកមកធ្វើរបាំងព្រួល រាប់រយម៉ែតនៅក្នុងទន្លេផង ។

ជាក់ស្តែងការដាក់សំរាស់នៅតាមដងស្ទឹង សង្កែខេត្តបាត់ដំបង ដែលចាប់ពីទីរួមខេត្ត បាត់ដំបងដល់ព្រែកទាល់មានសំរាស់ ៦០០ សំរាស់ ( Wayne ១៩៩៨ ) តែមកដល់ចុងខែធ្នូ ២០០១ មានសំរាស់ ១៦៧ ត្រូវបានគេរាប់ឃើញ

(FACT: March, ២០០២) ។ សំរាស់និមួយ១មានទំហំ ខុស១គ្នាដែលជាទូទៅមាន បណ្តោយពី៨-១៥ម៉ែត និង ទទឹង ពី៥-៨ម៉ែត តែជំរៅ ប្រែប្រួលទៅតាមជំរៅ ទឹក។ សំរាស់ធ្វើឡើងពី មែកឈើដែលភាគច្រើន







*ការកាប់ព្រៃលិចទឹក ដើម្បីធ្វើផ្លូវភ្លើង*

បានមកពីព្រៃលិចទឹក។ ក្នុងមួយសំរាស់ត្រូវការមែកឈើប្រហែលពី ១០០-៧០០ មែក ដែលគេយកវាទាំងអស់នេះមករៀបគរលើគ្នា ដោយធ្វើយ៉ាងណាអោយត្រី គិតថាជាព្រៃលិចទឹក ។

ឡូតិ៍នេសាទមួយចំនួនបានកាប់ឆ្ការព្រៃលិចទឹកធ្វើផ្លូវភ្លើងជារៀងរាល់ឆ្នាំ ដែលផ្លូវភ្លើងនិមួយ១មានទទឹង ២-៣ ម៉ែត និងបណ្តោយរាប់សិបគីឡូម៉ែតឯណោះ។ ការកាប់ផ្លូវភ្លើងនេះក៏រួមចំណែកបំផ្លាញព្រៃលិចទឹក មួយផ្នែកដែរ ។

## ៤.៥ ភ្លើងឆេះព្រៃ

ព្រៃលិចទឹកនៅតាមរឹមទន្លេសាបច្រើន ឆេះនៅរដូវប្រាំង(ទឹកស្រក)ចំពោះបញ្ហានៃការឆេះនេះកើតឡើងដោយសារសកម្មភាពពីរគឺ ដោយចេតនា និងដោយអចេតនាពីសំណាក់ប្រជាជនទាំងក្នុង និងក្រៅមូលដ្ឋាន។ ពេលរដូវទឹកសំរកប្រជាជនចាប់ផ្តើមកាប់ឆ្ការព្រៃលិចទឹក ធ្វើស្រែចំការអ្នកខ្លះខ្ជិលក៏ដុត ដែលធ្វើអោយរាលដាលដល់ព្រៃនៅក្បែរ១នោះ។ ក្រៅពីនេះនៅមានការដុតព្រៃចាប់សត្វឃ្មុំ អណ្តើក ពស់ គន្ធាយ....។ ជាក់ស្តែងនៅខែមេសា ឆ្នាំ ២០០៣ ព្រៃលិចទឹកនៅឡូតិ៍លេខ៨ ក្នុងខេត្តបាត់ដំបងត្រូវឆេះ ដែលក្នុងនោះផ្ទៃដីព្រៃលិចទឹករាប់សិបហិចតាត្រូវបានភ្លើងបំផ្លិចបំផ្លាញ។ ភ្លើងឆេះព្រៃនេះមិនត្រឹមតែបំផ្លាញព្រៃលិចទឹកប៉ុណ្ណោះទេថែមទាំងសំលាប់សត្វដែលអាស្រ័យក្នុងព្រៃនេះហើយប្រសិនបើវាមិនស្លាប់



*ទិដ្ឋភាពព្រៃលិចទឹកក្រោយភ្លើងឆេះ*

ទេវាក៏បាត់បង់ទីជំរកដែរ ។

នៅក្នុងខេត្តសៀមរាបនាពេលថ្មីនេះមានករណីភ្លើងឆេះព្រៃលិចទឹកអស់ប្រហែលជាង ១០០ហិចតា នៅក្នុងឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង។ ករណីភ្លើងឆេះព្រៃនេះបង្កឡើងដោយប្រជាជនមួយចំនួន ដែលនៅតំបន់ខាងក្រៅចូល



ទិដ្ឋភាពព្រៃលិចទឹកក្រោយភ្លើងឆេះ នៅកំពង់ភ្លុក

ទៅចំអិនអាហារនៅក្នុងពេលធ្វើការនេសាទរបស់ពួកគេ ហើយនៅពេលត្រលប់ទៅវិញ គេមិនបានពន្លត់ភ្លើង ទើបបង្កអោយមានភ្លើងឆេះនេះឡើង។ ភ្លើងឆេះព្រៃនេះចាប់ឆេះខ្លាំងនៅខាងកើតព្រែកប្រវឹក នៅថ្ងៃទី១៣កក្កដា ២០០៣ នេះ ហើយបន្តរីករាលដាលរហូតដល់ព្រៃកូនសត្វ។ នៅក្នុងថ្ងៃ១៤-១៥ ដោយមានការអន្តរាគមន៍ពីក្រុមពន្លត់អគ្គីភ័យទើបធ្វើអោយសកម្មភាពភ្លើងមានការថយចុះ តែដោយភ្លើងឆេះដុំក្នុងគល់ឈើធំៗទើបធ្វើអោយមានភ្លើងឆាបឆេះខ្លាំងម្តងទៀតនៅថ្ងៃទី ១៩។ ករណីភ្លើងឆេះនេះបានបំផ្លាញធនធានធម្មជាតិយ៉ាងច្រើនដូចជាជំរកសត្វ កន្លែងរកអាហារ កន្លែងបន្តពូជ....។

## ៤.៦ ការបំពុលទឹក

ព្រៃលិចទឹកជួយថែរក្សាគុណភាពទឹក ដោយព្រៃលិចទឹកបានផ្តល់នូវបរិមាណ $O_2$ ចូលទៅក្នុងទឹកយ៉ាងច្រើន និងស្រូបយកមកវិញនូវសមាសធាតុផ្សេងៗ ដូចជា $NO_2$, $NO_3$, $Ca(NO_4)_2$ (សមាសធាតុទាំងនេះធ្វើអោយទឹកខូច)។ ក៏ប៉ុន្តែលទ្ធភាពនេះត្រូវបានបាត់បង់ ដោយបឹងទន្លេសាបកំពុងទទួលរងនូវ ការបំពុលទឹកយ៉ាងខ្លាំង។ នៅចុងឆ្នាំ ២០០០ គេបានប៉ាន់ស្មានថា ថ្នាំពុល



ថ្នាំសំលាប់សត្វល្អិតដែលបានប្រើប្រាស់នៅបឹងទន្លេសាប





កសិកម្មប្រមាណជា ១.៣ លានលីត្រត្រូវបានប្រើនៅជុំវិញបឹងទន្លេសាប (សេដាក ២០០០) ហើយដេដេតេ និង ហ្វូលីដុល ប្រមាណ ១០ តោនក្នុងមួយឆ្នាំត្រូវបានប្រើលើផ្ទៃដីប្រមាណ ២០០០ហិចតា លើដំណាំសណ្តែកបាយ នៅតំបន់ទន្លេសាប (FAO. ២០០០)។ ម្យ៉ាងទៀតបញ្ហាកត្តាសត្វល្អិតចង្រៃ និងដីមិនសូវមានជីជាតិបានធ្វើអោយកសិករបង្កើនការប្រើថ្នាំពុលគីមី និងជីគីមីយ៉ាងច្រើនសន្ធឹកសន្ធាប់នៅជុំវិញបឹងទន្លេសាបក្នុងន័យសំរាប់បង្កើនទិន្នផលជាចាំបាច់ ដើម្បីផ្គត់ផ្គង់នូវអាហារអោយបានគ្រប់គ្រាន់ជាមួយនឹងកំណើនប្រជាជនដ៏ច្រើននៅទីនេះ។ ប្រសិនបើការបង្កើន



សំណល់រឹង នៅក្នុងបឹងទន្លេសាប



ការបំពុលទឹកនៅតំបន់ចុងឃ្នៀស សៀមរាប

ការប្រើប្រាស់នេះនៅតែបន្តធ្វើបែបនេះទៅទៀត ដោយគ្មានការកំណត់ និងពុំត្រឹមត្រូវទេនោះវានឹងបង្កអោយមានការបំពុលទឹកហើយលើសពីនេះទៅទៀតវានឹងប៉ះពាល់ដល់សុខភាពមនុស្ស និងសត្វ។ ទឹកពុល ធ្វើអោយប៉ះពាល់ដល់ ការលូតលាស់របស់ព្រៃលិចទឹក និងធ្វើអោយកូនឈើតូចៗអាចស្លាប់បាន។ ក្រៅពីនេះនៅមានកាកសំណល់ពីការកាប់បំផ្លាញព្រៃឈើនៅផ្នែកខាងលើនៃផ្ទៃរងទឹកភ្លៀងបឹងទន្លេសាប និងទឹកស្អុយដែលហូរពីចាក់ពីផ្នែកខាងលើនៃទន្លេមេគង្គ ។

## ៥ ប្រភេទសត្វដែលមាននៅក្នុងព្រៃលិចទឹក

នៅក្នុងព្រៃលិចទឹកពុំមានការសិក្សាណាដែលបញ្ជាក់យ៉ាងច្បាស់អំពីចំនួននិងប្រភេទសត្វដែលមាននៅក្នុងតំបន់នេះ ទេតែគេស្គាល់ប្រភេទសត្វមួយចំនួននៅក្នុងបឹងទន្លេសាបដែលសត្វទាំងនេះក៏មាននៅក្នុងព្រៃលិចទឹកដែរពីព្រោះព្រៃលិចទឹក ជាផ្នែកមួយនៃបឹងទន្លេសាប។ ហើយព្រៃ

លិចទឹកជាជំរកយ៉ាងល្អសំរាប់ការរស់នៅ បន្តពូជ និងគេចពីសត្រូវ សំរាប់សត្វស្លាប ត្រី សត្វល្មូន សត្វបាតបឹង និងសត្វល្អិត។

នៅក្នុងតំបន់ព្រៃលិចទឹកមានកំទេចកំទីជាច្រើនដែលមានប្រភពមកពីតំបន់ខាងលើបឹងទន្លេសាប និងមកពីការជ្រុះស្លឹកឈើ ការបាក់មែកឈើ និងអ្វីផ្សេងទៀតរបស់ព្រៃលិចទឹក ដែលកំទេចកំទីទាំងអស់នេះត្រាំនៅក្នុងទឹកបា ក្លាយទៅជាចំណីអាហាររបស់សត្វផ្សេងៗ ព្រោះ កំទេចកំទីទាំងនេះ វារលួយបង្កអោយមានសត្វ ប្លងតុង ដែលជាចំណីរបស់សត្វត្រីមួយចំនួនធំរស់ នៅក្នុងតំបន់នេះ។ នៅពេលដែលមានចំនួនប្លង តុងកាន់តែច្រើននោះព្រមទាំងអាកាសធាតុ អំណោយផលផងនោះ នាំអោយត្រីមានកាន់តែ

គំនូសបំព្រួញការកកើតចំណីធម្មជាតិដោយនាទីព្រៃលិចទឹក








ពិកម្មប្រមាណជា ១,៣ លានលីត្រត្រូវបាន ប្រើនៅជុំវិញបឹងទន្លេសាប (សេដាក ២០០០) ហើយដេដេតេ និង ពូលីដុល ប្រមាណ ១០ តោនក្នុងមួយ ឆ្នាំត្រូវបានប្រើលើ ផ្ទៃដីប្រមាណ ២០០០ហិចតា លើដំណាំសណ្តែក បាយ នៅតំបន់ ទន្លេសាប (FAO. ២០០០)។ ម្យ៉ាងទៀតបញ្ហាកត្តាសត្វល្អិតចង្រៃ និងដីមិនសូវមានជីជាតិបានធ្វើអោយកសិករ បង្កើនការប្រើថ្នាំពុលគីមី និងជីគីមីយ៉ាងច្រើន សន្ធឹកសន្ធាប់នៅជុំវិញបឹងទន្លេសាបក្នុងន័យ សំរាប់បង្កើនទិន្នផលជាចាំបាច់ ដើម្បីផ្គត់ផ្គង់នូវ អាហារអោយបានគ្រប់គ្រាន់ជាមួយនឹងកំណើន ប្រជាជនដ៏ច្រើននៅទីនេះ។ ប្រសិនបើការបង្កើន



សំណល់រឹង នៅក្នុងបឹងទន្លេសាប



ការបំពុលទឹកនៅតំបន់ចុងឃ្នៀស សៀមរាប

ការប្រើប្រាស់នេះនៅតែបន្តធ្វើបែបនេះទៅទៀត ដោយគ្មានការកំណត់ និងពុំត្រឹមត្រូវទេនោះវា នឹងបង្កអោយ មានការបំពុល ទឹកហើយលើសពី នេះទៅទៀតវា នឹងប៉ះពាល់ដល់ សុខភាពមនុស្ស និងសត្វ។ ទឹក ពុល ធ្វើអោយ ប៉ះពាល់ដល់ ការ លូតលាស់របស់ព្រៃលិចទឹក និងធ្វើអោយកូនឈើ តូចៗអាចស្លាប់បាន។ ក្រៅពីនេះនៅមានកាក សំណល់ពីការកាប់បំផ្លាញព្រៃឈើនៅផ្នែកខាង លើនៃផ្ទៃរងទឹកភ្លៀងបឹងទន្លេសាប និងទឹកស្អុយ ដែលហូរពីចាក់ពីផ្នែកខាងលើនៃទន្លេមេគង្គ ។

## ៥ ប្រភេទសត្វដែលមាននៅក្នុងព្រៃលិចទឹក

នៅក្នុងព្រៃលិចទឹកពុំមានការសិក្សាណា ដែលបញ្ជាក់យ៉ាងច្បាស់អំពីចំនួននិងប្រភេទសត្វ ដែលមាននៅក្នុងតំបន់នេះ ទេតែគេស្គាល់ប្រភេទ សត្វមួយចំនួននៅក្នុងបឹងទន្លេសាបដែលសត្វទាំង នេះក៏មាននៅក្នុងព្រៃលិចទឹកដែរពីព្រោះព្រៃលិច ទឹក ជាផ្នែកមួយនៃបឹងទន្លេសាប។ ហើយព្រៃ

លិចទឹកជាជំរកយ៉ាងល្អសំរាប់ការរស់នៅ បន្តពូជ និងគេចពីសត្រូវ សំរាប់សត្វស្លាប ត្រី សត្វល្មូន សត្វបាតបឹង និងសត្វល្អិត។

នៅក្នុងតំបន់ព្រៃលិចទឹកមានកំទេចកំទីជាច្រើនដែលមានប្រភពមកពីតំបន់ខាងលើបឹងទន្លេសាប និងមកពីការជ្រុះស្លឹកឈើ ការបាក់មែកឈើ និងអ្វីផ្សេងទៀតរបស់ព្រៃលិចទឹក ដែលកំទេចកំទីទាំងអស់នេះត្រាំនៅក្នុងទឹកបានក្លាយទៅជាចំណីអាហាររបស់សត្វផ្សេងៗ ព្រោះកំទេចកំទីទាំងនេះ វារលួយបង្កអោយមានសត្វប្លង់តុង ដែលជាចំណីរបស់សត្វត្រីមួយចំនួនធំរស់នៅក្នុងតំបន់នេះ។ នៅពេលដែលមានចំនួនប្លង់តុងកាន់តែច្រើននោះព្រមទាំងអាកាសធាតុអំណោយផលផងនោះ នាំអោយត្រីមានកាន់តែ

*គំនូសបំព្រួញការកកើតចំណីធម្មជាតិដោយនាទីព្រៃលិចទឹក*








ច្រើនដែលជាមូលហេតុទាក់ទាញមនុស្ស និងសត្វផ្សេងៗអោយមករស់នៅក្នុងតំបន់នេះកាន់តែច្រើនឡើង ។

ព្រៃលិចទឹកផ្តល់នូវចំណីដល់ វារីសត្វជាច្រើនជាពិសេសត្រីដោយកើតឡើងពីស្លឹក មែក ផ្លែ (ដែលទុំជ្រុះ) រលួយក្នុងទឹកបង្កើតបានជាសត្វប្លង់តុង រុក្ខជាតិប្លង់តុង និងសត្វស្រទាប់បាត (Zoobentos)។ ម្យ៉ាងទៀត សត្វល្អិតរស់នៅនឹងរុក្ខជាតិព្រៃលិចទឹកនៅ ពេលទឹកឡើងលិចព្រៃធ្វើអោយសត្វល្អិតទាំងនេះក្លាយទៅជាចំណីរបស់ត្រីដែរ។

## ៥.១ ប្រភេទត្រី

នៅរដូវទឹកជំនន់ពីខែឧសភាដល់តុលា ផ្ទៃបឹងមានវិសាលភាព ១-១,៥ លានហិចតា ដែលជាហេតុធ្វើអោយត្រីអាចទៅរស់នៅក្នុងព្រៃលិចទឹកបាន។ ស្លឹក ឫស និងមែកឈើព្រៃលិចទឹកទាំងនេះត្រូវបានត្រីយកធ្វើជាសំបុកសំរាប់ពងកូន និងលាក់ខ្លួនរបស់ត្រី ។

យើងដឹងហើយថានៅបឹងទន្លេសាបការនេសាទទទួលបានទិន្នផលត្រីខ្ពស់ និងមានប្រភេទត្រីជាច្រើនដែរ។ ក្នុងនោះប្រភេទត្រី ១០៧ ប្រភេទ ត្រូវបានកត់ត្រាទុក តែចំនួនពិតអាចលើសពីនេះច្រើនទៅទៀត ដែលប្រភេទត្រីទាំងនេះ ក៏អាចមាននៅក្នុងតំបន់ព្រៃលិចទឹកដែរ (ប្រភព: ADB, ២០០២)។ ប៉ុន្តែសព្វថ្ងៃនេះការនេសាទរបស់ប្រជាជនម្នាក់ៗទទួលបានទិន្នផលតិចជាងឆ្នាំមុន ហើយមានប្រភេទមួយចំនួនទៀតកំរនឹងឃើញណាស់សព្វនេះ។ នេះមានន័យថាប្រភេទនេះកំពុងតែឈានទៅរកការផុតពូជដូចជា ត្រីរាជ គល់រាំង...។ (តារាងប្រភេទត្រីមួយចំនួនមាននៅ ក្នុងឧបសម្ព័ន្ធទី៣)


*ត្រីគល់រាំង រឺ ត្រីកាហោ ដែលនេសាទបាននៅបឹងទន្លេសាប*

## ៥.២ សត្វឥតឆ្អឹងកង និងសត្វបាតបឹង

នៅក្នុងបឹងទន្លេសាបគេបានស្គាល់ ៤៦ ប្រភេទនៃ Zooplankton និងប្រភេទសិប្បីសត្វចំនួន ៥៧ ប្រភេទហើយនៅមានប្រភេទជា

ច្រើនទៀតដែលនៅមិនទាន់បានរកឃើញនៅឡើយ (ប្រភព: ADB, ២០០២)។

### ៥.៣ ថនិកសត្វ

នៅក្នុងតំបន់បឹងទន្លេសាបមានថនិកសត្វប្រហែលជាមាន៤៦ប្រភេទ ដូចជា ដំរី ខ្លាត្រី ភេ... ដែលសត្វទាំងនេះធ្វើដំណើរពីតំបន់ខ្ពង់រាបមកទីនេះដើម្បីរកអាហារ និងជាកន្លែងបន្តពូជ។ តែនៅសព្វថ្ងៃនេះស្ថិតិអំពីចំនួន និងប្រភេទនៃសត្វថនិកសត្វពុំមានឯកសារទាក់ទងច្រើននោះទេ តែគេស្គាល់ថាមានយ៉ាងហោចណាស់ ១៥ប្រភេទដែលមានរស់នៅក្នុងតំបន់នេះ (ប្រភព: ADB, ២០០២)។

តារាងលេខ៧: ប្រភេទថនិកសត្វមួយចំនួន

| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|
| • ស្វាក្តាម | • Macaca fascicularis |
| • ស្វាព្រាម | • Semnopithecus eristatus |
| • ភេរោមច្រមុះ | • Lutra sumatrana |
| • កំប្រុកពណ៌ | • Callosciurus finlaysonii |

*(ប្រភព: សៀវភៅថនិកសត្វនៅកម្ពុជា ឆ្នាំ២០០០)*

### ៥.៤ សត្វស្លាប

បឹងទន្លេសាបជាកន្លែងដែលសំបូរទៅដោយសត្វស្លាប។ តំបន់នេះជាកន្លែងជំរកសត្វស្លាបធំជាងគេនៅតណ្ឌចិនហើយ ប្រហែលជាកន្លែងដែលធំជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះផងដែរ។ នៅទីនេះមានប្រភេទសត្វស្លាបជាង ២២៥ ប្រភេទ ដែលបានកត់ត្រាកាលពីឆ្នាំ ១៩៦០ (ប្រភព: ADB, ២០០២)។ សត្វស្លាបភាគច្រើនរស់នៅក្នុងតំបន់ព្រៃលិចទឹក និងវាលស្មៅលិចទឹក។ (តារាងប្រភេទស្លាបមួយចំនួនមាននៅក្នុងឧបសម្ព័ន្ធទី២)។







*ជំរកសត្វស្លាបនៅតំបន់ព្រែកទាល់*

### ៥.៥ ល្មូន

ប្រភេទនៃសត្វល្មូននៅក្នុងបឹងទន្លេសាប រាប់បញ្ចូលទាំងសត្វដែលរស់នៅគោកផង និងក្នុងទឹកផងនោះនៅតំបន់នេះមានប្រហែលជា ៤២ ប្រភេទ ដែលទាំងនេះជាឯកសារកាលពីមុន តែសព្វថ្ងៃនេះពុំមានការសិក្សាណាបញ្ជាក់ អោយច្បាស់លាស់នោះទេ (ប្រភព: ADB, ២០០២)។



*ពស់ដែលចាប់បានពីព្រៃលិចទឹក*

## ៦. សន្និដ្ឋាន

ព្រៃលិចទឹកបឹងទន្លេសាបមានសារៈសំខាន់ណាស់សំរាប់ជាកន្លែងត្រីជ្រកពងកូន ហើយវាអាចជួយទប់ទល់នឹងគ្រោះធម្មជាតិបានមួយចំនួន និងធ្វើអោយបរិស្ថានក្នុងមជ្ឈដ្ឋានមានភាពបរិសុទ្ធ។ ដែលវាអាចធ្វើអោយការរស់នៅរបស់ប្រជាជនយើងនៅក្នុងតំបន់នេះមានលក្ខណៈល្អប្រសើរដោយមានបរិស្ថានរស់នៅល្អ ទិន្នផលត្រីនៅទីនេះមានច្រើន និងសំបូរទៅដោយសត្វផ្សេងៗជាច្រើនដូចជា សត្វស្លាប ល្មូន...។ តែសព្វថ្ងៃនេះព្រៃទាំងអស់នោះកំពុងតែទទួលការគំរាមកំហែងពីសេចក្តីត្រូវ ការសំរាប់ធ្វើអុសធ្យូង និងការកាប់ឆ្ការព្រៃយកដីធ្វើកសិកម្មរបស់ប្រជាជនក្នុង និងក្រៅតំបន់។ ការបាត់បង់ព្រៃទាំងនេះ នឹងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើផលិតភាពនៃបឹងទន្លេសាប ពីព្រោះដោយសារអវត្តមាននៃដើមឈើព្រៃលិចទឹកទាំងនោះបាត់បង់តួនាទីជាកន្លែងផលិតអាហារសំរាប់ត្រី និងកន្លែងពងកូនបន្តពូជ ហើយកូនត្រីតូចៗងាយទទួលរងនូវការអន្តរាយ។ នៅពេលដែលទិន្នផលត្រីនៅទីនេះមានការថយចុះនឹងឥទ្ធិពលមិនល្អដល់មនុស្សនិងសត្វផ្សេងៗដែលរស់នៅទីនេះ ។

## ៧ ឯកសារយោង


- ក្រសួងបរិស្ថាន. ២០០០. *ជំនួយស្មារតីបរិស្ថាន*
- ក្រសួងបរិស្ថាន. ២០០១. *របាយការណ៍ស្តីពីស្ថានភាពជីវចំរុះនៅកម្ពុជា*
- សិក្ខាសាលាស្តីពីការអភិរក្សធនធានធម្មជាតិជលផល. ខេត្តបាត់ដំបង. ២០០២
- FACT, 2002. *ស្ថានភាពនេសាទរបស់ប្រជានេសាទនៅខេត្តបាត់ដំបងក្រោយពេលកែទំរង់វិស័យជល*
- នាយកដ្ឋានរុក្ខាប្រមាញ់. ១៩៩៤. *រុក្ខជាតិនៅកម្ពុជា*
- នាយកដ្ឋានរុក្ខាប្រមាញ់. ២០០៣. *ស្ថិតិវិស័យព្រៃឈើកម្ពុជាត្រឹមឆ្នាំ២០០២*







- អ៊ូ សិទ្ធិរិទ្ធិ. ១៩៩៦. *ការសិក្សាពីប្រភេទព្រៃលិចទឹក ក្នុងខេត្តសៀមរាប*
- អ៊ិន ហ៊ុល. ១៩៩៥. *ឥទ្ធិពលជីវសាស្ត្រ និង បរិស្ថានព្រៃលិចទឹក ក្នុងខេត្តសៀមរាប*
- CFDS, *ប្រភេទត្រីដែលមាននៅបឹងទន្លេសាប និងអាងទន្លេមេគង្គ*
- CDRI, 2002. *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា*
- មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង. ២០០១: *ការរៀបចំសហគមន៍នេសាទ នៅខេត្តបាត់ដំបង*
- បទអន្តរាគមន៍របស់មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ
- ការវាយតំលៃធនធានធម្មជាតិសំរាប់ការអភិវឌ្ឍន៍ សហគមន៍ព្រៃលិចទឹក និងនេសាទ ឃុំចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប
- ការត្រួតពិនិត្យវាយតំលៃលើវិស័យជលផល ក្នុងសៀមរាប
- CEDAC, 2001. *ស្ថានភាពនៃការប្រើប្រាស់ថ្នាំពុលនៅជុំវិញបឹងទន្លេសាប*
- ទស្សនាវដ្តី *សំលេងប្រជានេសាទ.* ឆ្នាំទីមួយ លេខទី ២ ឆ្នាំ២០០៣
- Mekong River Commission Secretariat/UNDP, 1998, Volume 2, Part 2.*Natural Resources-Based Development Strategies for The Tonle Sap Area*
- Mak Sithirith, 2000. *Fishing for live: Conflicts and Struggles and Fishing Lots in Kompong Chhang Province*
- MDRN Team, 1995 (Phase II). *An Environmental Study of The Mekong Basin in The Kingdom of Cambodia: The Geat Lake/Tonle Sap Ecosystem*
- Hong Chamnam, 2001. *Conservation Activities at Ang Trapesng Thmor Sarus Crane Conservation Area 1998-2000*
- ADB, 2002. *Report and Recommendation for the Tonle Sap Environment Management Project*

**ឧបសម្ព័ន្ធទី ១:** បញ្ជីរាយនាមឈ្មោះរុក្ខជាតិដែលដុះក្នុងតំបន់ព្រៃលិចទឹក

| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| រាំងទឹក | Barringtonia acutangula | ខ្លាស់ | Diospyros sylvatica |
| ច្រកែង | Coccoceras anisopsdum | ទន្លាប់ | Diospyros sp. |
| ក្របៅផ្លែធំ | Hydoncarpus saigonensis | អំពិលទឹកព្រៃ | Cynometra (dongaiensis) |
| ស្ទី | Crudia chrysantha | អញ្ចាញ | Gmelina asiatica |
| រទាំងឬអាទាំង | Homalium griffithianum | ដៃខ្លា | Gardenia ? |
| តាសែង | Xanthophyllum cf.glaucum | ក្រាស់ | Samandura harmendii |
| សេដា ក្រហម | Cryptocarya oblongifolia | ? | Dreypetes thorelii |
| ផ្ទោល | Diospyros cf.bejaudii | រំដេញ ក្អែក | Elaeocarpus madoptalus |
| សណ្តាន់ | Gaceinia cf.loureiri | រំដេញទឹក | Elaeocarpus sp. |
| រាំងទឹក | Barringtonia microantha | ខ្ទម្ពទឹក | Stephegyne (diversifolia ?) |
| ក្របៅផ្លែតូច | Hydnocarpus authelminthi-cal | ភ្នំភ្លើង | Hymenocardia wallichii |
| ចំរៀក | Albizia lebekkoides | ប្របួយ | Croton caudatus |
| រទាំងឬអាទាំង | Homalium brevidens | ប្រផេញឈ្មោល | Phyllanthus |
| ត្នូរ | Terminalia cambodiana | កញ្ចើបាយដាច | Capporia microcantha |
| សេដា ស | Lophopetalum fimbriatum | ? | Styxis harmandiana |





| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ស្វាយទឹក | Grewia sinuata | ញរទឹក | Morinda pericaefolia |
| ទន្លាប់ | Crataeva nurvala | ក្រជៀម | Pentapetes pheonicea |
| ភ្អែកព្រាប | Breynia rhamnoides | រៃទឹក | Homoonoia riparia |
| ? | Alangium cf.costrastum | ផ្តៅទឹក | Calamus (godofroyi) |
| ចា | Butea frondosa | វល្លិត្រគ្រោះ | Combretum trifoliatum |
| ផ្តុល | Mimusops ? | សង្ស័រ | Uncaria homomalla |
| ឪជ្រើង | Cordia sp. | វល្លិខ្យូស | Calycopteris floribunda |
| រំដេញ ភ្លុក | Elaeocarpus griffthii | បាយត្រណើប | Aeacia spiralis |
| ខ្ទម្ព | Stephegyne parvifolia | វល្លិជុយ | Parameria glandulifera |
| ឫស្សីព្រៃ | Bambusa arundinacea | ? | DAlbergia Entadoides |
| ? | Croton krabas | វល្លិព្រះ | Quisqualis densiflora |
| ប្រផេញញី | Phyllanthus taxodiifolius | ? | Hiptage triacantha |
| តាស្បៀវ | Phyllanthus | ? | Uvaria pierrei |
| ទៀនព្រៃ | Vitex Hceloadenon | ? | Ipomoea chryseides |
| ? | Schoutenia godenfroyana | ឃ្លេ | Cudrania cambodiana |
| ស្លូត | Ficus heterophylla | ? | Buettneria pilosa |

**ឧបសម្ព័ន្ធទី ២**: បញ្ជីរាយនាមឈ្មោះសត្វស្លាបទឹកសំខាន់ៗមួយចំនួន

| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| សត្វខ្សឹប រឺ ធ្លាក់អណ្តូត រឺ អាអ៊ិតមហាចោរ | Eupodotis bengalensis | ទាព្រៃកន្ទុយវែង | Anas acuta |
| | | គ្រួចអិនទ្រូងលាត | Mirafra javanica |
| ត្មាតភ្លើង | Sarcogyps calvus | ពពូកទឹក | Heliopais personata |
| ស្មោញ | Anghinga malanogaster | អកត្រីកំរ | Haliaeetus leucorypbus |
| ក្ងួនខ្មៅ | Pseudibis davisoni | អកខ្មៅជីសើម | Aquila calnga |
| រនាលស | Mycteria cinerea | ក្ងួនស | Threskiornis melano-cephalus |
| អង្កត់ខ្មៅ | Ephippiorhynchos asisticus | ទុងប្រផេះ | Pelecanus philippensis |
| ត្រដក់ធំ | Leptoptilos dubius | រនាលពណ៌ | Myteria leucocephala |
| គ្រួចទ្រូងខៀវ | Coturnix chinensis | ត្រដក់តូច | Leptoptilos javanicus |
| ត្រសេះមធ្យមខ្មៅ-ស | Dendrocopos macei | ចាបពូកទ្រូងលឿង | Ploceus hypoxanthus |
| | | ទាកាប៉ាព្រៃ | Sarkidiornis melanotos |
| ខ្លែងខ្មៅ | Milvus migrans | ត្រដេវចទន្លេ | Duvancelii |
| រអាតត្នោត | Butastur livanter | អកសមុទ្រ | Haliaeetus leucogaster |
| ខ្វែកខ្យល់ | Botaurus stellaris | ក្អែកទឹកធំ | Phalacrocorax carbo |
| សត្វកស រឺកុកស | Ciconia episcopus | ចង្កៀលខ្យង | Anastomus oscittans |





| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ចាបពណ៌មាស រឺ ចាបចង្រុងក្រហម | Amandava amandava | ខ្វែកគ្រាកកន្ទុយមូល | Rostratula benghalensis |
| ចាបអ៊ឺរ៉ុប | Passer domesticus | អកត្រីក្បាលប្រផេះ | Chthyaetus ichthyophaga |

**ឧបសម្ព័ន្ធទី ៣**: បញ្ជីរាយនាមឈ្មោះត្រី

| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ត្រី ក្រាយ | Chitala blanci | ត្រី ដងដាវ | Luciosoma setigerum |
| ត្រី ក្រាយវា | Chitala ornata | ត្រី ចង្វាស្រលូង | Rasbora sp. cf. beauforti |
| ត្រី ? | Megalops cyprinoides | ត្រី ស្លាត | Chitala lopis |
| ត្រី កណ្ដូល អំពៅ | Corica laciniata | ត្រី ស្លាតតូច | Notopterus notopterus |
| ត្រី ក្បក | Tenualosa thibaudeui | ត្រី កណ្ដូល អំពៅ | Clupeoides borneensis |
| ត្រី ឆ្លាក្រពើ | Lycothrissa crocodilus | ត្រី កណ្ដូល អំពៅ | Clupeichthys aesarnensis |
| ត្រី ស្លឹកឫស្សី | Paralaubuca typus | ត្រី ជន្លួញមាន់ | Coiloa lindmani |
| ត្រី ស្លឹកឫស្សី ស្រែ | Oxygaster pointoni | ត្រី ឆ្មា | Setipinna melanochir |
| ត្រី ជន្ទាសភ្លុកក្រហម | Parachela oxygastroides | ត្រី ដងខ្មែង | Macrochirichthys macrochirus |
| | | ត្រី ជន្ទាសភ្លុក | Parachela maculicauda |
| ត្រី សកាកែវ | Raiamas guttalus | ត្រី ជន្ទាសភ្លុកស | Parachela sainmensis |
| ត្រី ? | Opsarius puichellus | ត្រី ចង្វា | Opsarius koratensis |
| ត្រី ? | Chela caeruleostigmata | ត្រី ចង្វាស្រែ | Amblypharyngadon chulaborna |
| ត្រី ចង្វាភ្លៀង | Esomus longimanus | ត្រី ចង្វាស | Danio aequipinnatus |
| ត្រីព្រលូង | Leptobarbus hoeveni | ត្រី ចង្វាភ្លៀងវែង | Esomus metallicus |





| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ត្រី បង្គួយ | Rasbora aurotaenia | ត្រី ចង្វាឆ្នូតតូច | Rasbora paucisquamis |
| ត្រី ចង្វាមូល | Rasbora aurotaenia | ត្រី ចង្វាកោង | **Rasbora spilocerca** |
| ត្រី ចង្វាពោត | Rasbora borapetensis | ត្រី ចង្វាពោត | **Rasbora trilineata** |
| ត្រី ចង្វាខ្នងវែង | Rasbora dusonensis | ត្រី កាប | Thryssoeypris tonlesapensis |
| ត្រី ចង្វាឆិត | Rasbora daniconius | ត្រី ត្រសក់ស | **Probarbus labeamajor** |
| ត្រី ចង្វាឆ្នូត | Rasbora espei | ត្រី ក្ងោរក្រហម | Tor tambroides |
| ត្រី ចង្វា | Rasbora pauciperforata | ត្រី កំប៉ុតច្រមុះ | Amblyrhynchichthy truncatus |
| ត្រី ចង្វាក្បាលធំ | Rasbora paviei | ត្រី ក្រុស | Cyclocheilichthys apogon |
| ត្រី ចង្វាមូល | Rasbora tornieri | ត្រី ឆ្កោក | Cyclocheilichthys enoplos |
| ត្រី ចង្វាឆ្នូត | Rasbora urophthatmoides | ត្រី ឆ្កោកភ្លើង | Cyclocheilichthys furcatus |
| ត្រី ត្រសក់ | Probarbus jullieni | ត្រី កន្ទុយក្រហម | Discherodontus ashmeadi |
| ត្រី ក្ងោរ | Tor sinensis | ត្រី ? | Mystacoleucus sp. |
| ត្រី ឆ្កោកទិទុយ | Albulichthys albuyloides | ត្រី ច្រកែងប្រាក់ | Puntioplites proctozysrom |
| ត្រី កំពូលបាយ | Cosmochilus harmandi | ត្រី ច្រកែងលឿង | Sikukia stejnegeri |
| ត្រី ផ្កាគ | Cyclocheilichthys armatus | ត្រី ខ្ពិនប្រាក់ | Barbodes gonionotus |
| ត្រី ចង្វាស | Rasbora myersi | ត្រី ខ្ពិន | Hypsibarbus lagleri |

| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ត្រី លលកស | Poropuntius deauratus | ត្រី ខ្ពិនមាស | Hypsibarbus malcolmi |
| ត្រី ប៉ាផាត់ | Scaphognathops bandanensis | ត្រី លលកសធំ | Poropuntius laosesins |
| ត្រី ខ្នាន់ | Hampala macrolepidota | ត្រី ច្រកែងមាស | Scaphognathops ste-jnegeri |
| ត្រី អង្កត់ប្រាក់ធំ | Systomus aurotaeniatus | ត្រី អង្កត់ប្រាក់ធំ | Puntius brevis |
| ត្រី អំពិលទុំ | Systomus orphoides | ត្រី អង្កត់ប្រាក់លឿង | Systomus bitnotatus |
| ត្រី ? | Systomus n. sp | ត្រី ខ្លា | Systomus partipentazona |
| ត្រី លិញ | Thynnichthys thynnoides | ត្រី កាហោធំ | Catlocarpio siamensis |
| ត្រី ព្រួលថ្ម | Barbichthys nitidus | ត្រី ប៉ាវ៉ាមុខពីរ | Banganabehri |
| ត្រី ក្រឡង់ធំ | Cirrhinus microlepis | ត្រី ផ្កាចា | Cirrhinus jullieni |
| ត្រី ស្រកាក្អាម | Cyclocheilichthys repasson | ត្រី ផ្ទាត | Cirrhinus prosemion |
| ត្រី ទឹមព្រឹក | Mystacoleucus marginatus | ត្រី ខ្នងវែងធំ | Dangila lineata |
| ត្រី ច្រកែងធំ | Puntioplites falcifer | ត្រី រៀលអង្កាម | Henicorhynchus cryp-topogon |
| ត្រី កំបុតច្រមុះ | Sikukia hudgeri | ត្រី ខ្នងវែង | Dangila sp. ct. cuvieri |
| ត្រី កាហែលក្រហម | Barbodes altus | ត្រី អាចម៍កុក | Dangila spilopleura |
| ត្រី កាហែលលឿង | Barbodes schwanefeldi | ត្រី លលកស | Osteochilus schlegeli |





| ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអ្នកស្រុកហៅ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ត្រី រៀល | Henicorhynchus siamensis | ត្រី ប៉ាវ៉ាមុខមួយ | Labeo erythropterus |
| ត្រី ប៉ាវ៉ា | Lobocheilos davisi | ត្រី ចង្វារនោង | Lobocheilos melanotaenia |
| ត្រី ប៉ាវ៉ាតូច | Lobocheilos quadrilineatus | ត្រី ក្អែក | Morulius chrysophekadion |
| ត្រី ក្រុសក្រហម | Osteochilus hasselti | ត្រី ក្រុស | Osteochilus lini |
| ត្រី ត្រុំ | Osteochilus melanopleurus | ត្រី ក្រុសលឿង | Osteochilus microcephalus |

**ឧបសម្ព័ន្ធទី ៤**: ស្ថានប្រព័ន្ធសំខាន់ៗនៅកម្ពុជា

